ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# ភាសាខ្មែរ

៦



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

www.elibraryofcambodia.org

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

## ថ្នាក់ទី ៦

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

www.elibraryofcambodia.org

**គណៈកម្មការនិពន្ធ** លោកស្រី ឈិន ស៊ីវឡេង លោក យ៉ង់ កំសាន
លោកស្រី ស៊ុន សូម៉ាណា លោកស្រី ជា ចាន់តារី

**អ្នកវាយអត្ថបទ** លោក អ៊ុំ បុប្ផា

**វិចិត្រករ** លោក ឃុន សុវណ្ណរិទ្ធី

**អ្នករៀបរៀង** លោកជំទាវ ទន់ សាអ៊ឹម

**អ្នករចនាគំរប** លោក ខែម ម៉ារី

**គណៈកម្មការពិនិត្យ** លោកស្រី យ៉ក់ បូឡែន លោកស្រី ឃាត ថារី

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២៧២០ អយក.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ 2016

ISBN 9-789-995-001-438

www.elibraryofcambodia.org

# អារម្ភកថា

ប្អូនៗកុមារា កុមារី ជាទីស្នេហា !

សៀវភៅភាសាខ្មែរថ្នាក់ទី៦នេះ ត្រូវបាននិពន្ធតាមកម្មវិធីសិក្សាថ្មី ។ សៀវភៅនេះនឹងជួយប្អូនៗក្នុងការអភិវឌ្ឍចំណេះដឹងគ្រឹះផ្នែកភាសាខ្មែរដូចជា បំណិនអាន សរសេរ ស្ដាប់ និងនិយាយ ។ ខ្លឹមសារនៃសៀវភៅនេះទាក់ទងនឹងប្រធានបទល្អៗដូចជា ទំនៀមទម្លាប់ ប្រពៃណីខ្មែរ ជំនឿ សាសនា តន្ត្រី សិល្បៈ ទេសចរណ៍និងចំណេះដឹងសំខាន់ៗជាច្រើនទៀតដែលមានប្រយោជន៍សម្រាប់ប្អូន ។

តាមរយៈសៀវភៅនេះប្អូនៗនឹងបានសិក្សាកំណាព្យ រឿងនិទាន អត្ថបទសន្ទនា លំហាត់អាន និងលំហាត់សរសេរងាយៗដែលប្អូនអាចយល់ និងអាចធ្វើបានគ្រប់មេរៀន ។ ជាពិសេសនៅចុងបញ្ចប់នៃមេរៀននីមួយៗ ប្អូននឹងអាចធ្វើការស្ទាបស្ទង់សមត្ថភាពខ្លួនផ្ទាល់ដើម្បីធ្វើស្វ័យវាយតម្លៃលើការសិក្សាកន្លងមក ។

ដោយឡែក នៅផ្នែកខាងក្រោយនៃសៀវភៅនេះ មានបទានុក្រមដែលអាចជួយប្អូនៗឱ្យបានយល់ដឹងអំពីន័យរបស់ពាក្យពិបាក ដែលមាននៅក្នុងសៀវភៅនេះ និងសូរអានរបស់ពាក្យនីមួយៗដែលប្អូនអាចហាត់អានពាក្យទាំងនោះ មុននឹងអានអត្ថបទនៅក្នុងមេរៀន ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅភាសាខ្មែរថ្នាក់ទី៦ ថ្មីនេះ អាចផ្ដល់ចំណេះដឹងល្អៗ ដើម្បីពង្រឹងសមត្ថភាពភាសាខ្មែរនិងជួយឱ្យសតិបញ្ញាស្មារតីចម្រើនលូតលាស់រាប់រហ័ស ។

សូមឱ្យប្អូនៗទទួលបានជោគជ័យក្នុងការសិក្សា ។

គណៈកម្មការនិពន្ធ

www.elibraryofcambodia.org

# បញ្ជីអត្ថបទ


មេរៀនទី១ : អ្នកមានគុណ ........................................ ១

មេរៀនទី២ : ក្ដីសង្ឃឹមរបស់កុមារ ........................................ ១៧

មេរៀនទី៣ : ធនធានរ៉ែនៅប្រទេសកម្ពុជា ........................................ ៣៣

មេរៀនទី៤ : ប្រយោជន៍នៃធម្មជាតិ ........................................ ៤៧

មេរៀនទី៥ : ធនធានជលផលនៅកម្ពុជា ........................................ ៦១

មេរៀនទី៦ : ទំនៀមទម្លាប់ ប្រពៃណីខ្មែរ ........................................ ៧៧

មេរៀនទី៧ : តន្ត្រីនិងសិល្បៈបុរាណ ........................................ ៨៩

មេរៀនទី៨ : ជំនឿនិងសាសនា ........................................ ១០១

មេរៀនទី៩ : រមណីយដ្ឋានទេសចរណ៍នៅកម្ពុជា ........................................ ១១៥

មេរៀនទី១០: សេចក្ដីថ្លៃថ្នូរ ........................................ ១២៩

តែងសេចក្ដី : ........................................ ១៤១

បទានុក្រម : ........................................ ១៤៥


www.elibraryofcambodia.org

មេរៀនទី ១

# អ្នកមានគុណ



អ្នកមានគុណ គឺអ្នកដែលបានធ្វើអំពើល្អគ្រប់បែបយ៉ាងដូចជា ចិញ្ចឹមបីបាច់ ថែទាំ ទូន្មានប្រៀនប្រដៅបង្ហាត់បង្រៀន និងឧបត្ថម្ភគាំទ្រដល់យើង ។ អ្នកមានគុណមានមាតា បិតា ជីដូនជីតា បងប្អូន គ្រូបាអាចារ្យ និងឧបការី ឧបការិនីដទៃទៀតដែលបានជួយទំនុកបម្រុងយើង ។

យើងត្រូវតបស្នងគុណអ្នកទាំងនោះឱ្យបានសមរម្យ ។



www.elibraryofcambodia.org

# ការប្រើវចនានុក្រម




ពេលអ្នកអានអត្ថបទអ្វីមួយហើយជួបប្រទះពាក្យដែលអ្នកមិនចេះអាន ឬមិនយល់ន័យ អ្នកអាចបើកមើលក្នុងវចនានុក្រម ។ វចនានុក្រមនឹងបង្ហាញអ្នកអំពីសូរអាន ថ្នាក់ពាក្យ ប្រភេទ និងសេចក្តីពន្យល់ន័យរបស់ពាក្យនោះ ។ មុននឹងប្រើវចនានុក្រម អ្នកគប្បីស្គាល់អក្សរសង្ខេបនិងគ្រឿងសម្គាល់ខ្លះៗជាមុនសិន ។

ចូរអ្នកសិក្សាអក្សរសង្ខេបមួយចំនួនខាងក្រោម ៖

| | | |
|---|---|---|
| កិ. គឺកិរិយា | ច្រ. ប្រ. គឺច្រើនប្រើជា | បា. ស. គឺបាលីនិងសំស្ក្រឹត |
| កិ. នុ. គឺកិរិយានុគ្រោះ | ន. គឺនាមសព្ទ | បារ. គឺបារាំង |
| កិ. វិ. គឺកិរិយាវិសេស | និ. គឺ និបាតសព្ទ | ម. ព. គឺមើលពាក្យ |
| ក្ល. ម. គឺក្លាយមកជា | ប. គឺបរិវារសព្ទ | យ. គឺយួន(ភាសាយួន) |
| គុ. គឺគុណនាម | បា. គឺបាលី | រ. ស. រាជសព្ទ |
| ច្រ. ន. គឺច្រើននិយាយថា | បា. ក្ល. គឺបាលីក្លាយ | ឡ. គឺឡាវ(ភាសាឡាវ) |
| | | ស. គឺសៀម(ភាសាសៀម) |



www.elibraryofcambodia.org

ពាក្យនៅខាងដើមជួរនីមួយៗ ជាពាក្យដែលត្រូវពន្យល់ ។ ពាក្យនេះ ហៅថា " មេពាក្យ " ។ គេសរសេរមេពាក្យដោយប្រើអក្សរធំ ខិត ។ គេតម្រៀបមេពាក្យទាំងនោះ តាមលំដាប់តួអក្សរ (លំដាប់ព្យញ្ជនៈនិងលំដាប់ស្រៈ) ។ អក្សរក្នុងវង់ក្រចកជាសូរអានមេពាក្យ ។ អក្សរកាត់នៅបន្ទាប់ពីសូរអានគឺជាថ្នាក់ពាក្យ រីឯអក្សរកាត់នៅក្នុងវង់ក្រចកបន្ទាប់ពីថ្នាក់ពាក្យ ប្រាប់ប្រភពរបស់ពាក្យនេះ ។ បន្ទាប់ពីថ្នាក់ពាក្យ ឬប្រភពពាក្យ គឺជាសេចក្ដីពន្យល់ន័យរបស់មេពាក្យ ។

ខាងក្រោមនេះ ជាគំរូខ្លះនៃវចនានុក្រមខ្មែរ (គេនិយមហៅថាវចនានុក្រមសម្ដេចជួន ណាត) ៖

**កវី** (ក:វី) ន. (សំ. បា. កវិ) អ្នកប្រាជ្ញដែលចេះតែងកាព្យឃ្លោង (អ្នកប្រាជ្ញខាងសម្ដី) ។

**កវីនិពន្ធ** (-និពន់) ន. (បា. កវិ+និពន្ធ) កវីជាអ្នកនិពន្ធ អ្នកនិពន្ធខាងកាព្យឃ្លោង ។

**កសិកម្ម** (ក: សិ កាំ) ន. (បា.) ការភ្ជួររាស់ ការងារដែលគេប្រកបក្នុងការភ្ជួររាស់ គឺការធ្វើស្រែចម្ការ ។

**កសិករ** (-ក) ន. ឬ គុ. (បា.) ។ ម. ព. កសិការ ។

**កសិការ** (-កា) ន. ឬ គុ. (បា.) អ្នកធ្វើកសិកម្ម ។

**កសិណ** (ក:-សិន) គុ. (បា.) "ទាំងអស់" ។ ន. រូបគាំងជាសម្គាល់ : កសិណសាក្សី យើងនឹងយកពាក្យនេះជាកសិណ មិនបានទេ ។

**កា ១** ន. បំពង់សម្រាប់ដាក់ទឹក ធ្វើដោយលោហធាតុផ្សេងៗ ឬដោយពិលាយពណ៌ : កាទឹក ។

**កា ២** កិ. សរសេរអាសយដ្ឋាន គឺសរសេរចុះឈ្មោះលំនៅអ្នកដែលនឹងទទួលសំបុត្រ នៅស្រោមសំបុត្រដែលនឹងផ្ញើទៅ : *កាស្រោមសំបុត្រ*សរសេរថែមសេចក្ដីផ្សេងៗលើខ្នងសំបុត្រជាសញ្ញា : *កាខ្នងសំបុត្រ* ។

**កាកគតិ** (កាក-គ: តិ) ន. (បា.) ឈ្មោះបទកាព្យពាក្យ ៤ (បទដំណើរក្អែកហោក) : នេះគឺច្បាប់ក្រម ប្រសើរឧត្ដម ខ្ញុំខ្លានអ្នកផង ប្រើនិងលំនោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង កើតដោយប្រណីបិតន៍... ។

វចនានុក្រម គឺជាបញ្ជីពាក្យដែលត្រូវបានរៀបតាមអក្ខរក្រម (លំដាប់អក្សរ) ដោយមានសូរអាន ថ្នាក់ពាក្យ ប្រភពពាក្យ និងសេចក្ដីពន្យល់ន័យមេពាក្យ ។



www.elibraryofcambodia.org

## លំហាត់

ក. ចូរអានពាក្យខាងក្រោម រួចប្រាប់ថ្នាក់ពាក្យ និងន័យមេពាក្យក្នុងវចនានុក្រម៖

**បរិបូរ** (ប-រិបូរ ឬ ប-បូ) គុ. (បា. សំ.) ដែលគ្រប់គ្រាន់ ដែលពេញគ្រប់គ្រាន់ ពេញលេញ សម្បូរ ដែលឆ្អែតហើយ : ម្ហូបចំណីបរិបូរ ។

**បរិភោគ** (បរិភោគ) ន. (បា. សំ.) ការចម្អែតអាត្មា(ស៊ី) ។

**បរិយាយ** (បរិយ៉ាយឬប-) ន. (បា. សំ. បរ្យាយ) សេចក្ដីអធិប្បាយដោយផ្សេងផ្សំ ការអធិប្បាយសម្រួលសេចក្ដី : ពោលដោយបរិយាយ ។

**បរិសុទ្ធ** (បរិសុត) គុ. (បា.) ដែលស្អាត ឥតសៅហ្មង : ចិត្តបរិសុទ្ធ ។

**បវរ** (បវរ) គុ. (បា. សំ. ប្រវរ) ប្រសើរ លើសលែង ថ្លៃថ្លា : ទ្រព្យដ៏បវរ ។

**បរិវត្ត** (ប៉ះរិវ៉ាត់) គឺ ប្រព្រឹត្តប្រឆាំង ប្រែប្រួល កែប្រែ ផ្លាស់ប្ដូរ (របបគ្រប់គ្រងដើម្បីឱ្យបានចម្រើន) ។

**បដិសេធ** (ប៉ះដិសែត) គឺ (បា. សំ.) ឃាត់ឃាំង លើកចោល ឬទាត់ចោលលែងយកជាការ លែងរាប់អាន: បដិសេធពាក្យ ។

**បឋម** (ប៉ះ ឋះ ម៉ះ ឬ ប៉ះ ថំ) ឬ សំ ឬ គុ. (បា. សំ. ប្រថម) ដំបូង មុន មុនគេ ទី១ : គ្រាបឋម ។

**បណ្ណាគារ** (ប៉ុន-ណា-គារ) ន. (បា. សំ. បណ្ណាគារ) ផ្ទះដាក់សៀវភៅ, សាស្ត្រា, ក្បួន, ច្បាប់ ។

ខ. ចូររៀបពាក្យខាងក្រោមឱ្យត្រូវតាមលំដាប់អក្សរ រួចពន្យល់ន័យពាក្យទាំងនេះដោយប្រើវចនានុក្រម ។

១. សោមនស្ស

២. មាតា

៣. ឧបត្ថម្ភ

៤. គង្គា

៥. ឧបការី

៦. មេត្តា ។

គ. ចូរបង្កើតល្បះដោយប្រើពាក្យនីមួយៗខាងលើ ។



www.elibraryofcambodia.org

# កតញ្ញូប្រាំប្រការ



(បទពាក្យប្រាំពីរ)

កូនត្រូវតបគុណម្ដាយនឹងពុក
ផ្គត់ផ្គង់ហូបចុកគ្រឿងនានា
ស្លៀកបំពាក់ថ្នាំការពារ
ឈឺគ្រុនរងាញ័រញាក់ក្ដៅ ។
ត្រូវជួយធុរៈអ្នកមានគុណ
កាប់កាស់វែកពុនកុំហ្មងសៅ
ទោះបីនឿយហត់ត្រជាក់ក្ដៅ
មើលថែម៉ែឪឱ្យលោកស្រាន្ត ។
ត្រូវចេះរក្សាពូជពង្សញាតិ
មិត្តភក្តិផងទៀតផៅសន្តាន
កេរ្តិ៍ឈ្មោះត្រកូលឱ្យថ្កើងថ្កាន
ជៀសវាងឱ្យបានកុំទាស់គ្នា ។
កូនត្រូវបម្រើអ្នកមានគុណ
វាចាទន់ភ្លន់គ្រប់វេលា
ព្រោះជាព្រះរស់នៃបុត្រា
កូនត្រូវវន្ទាដោយភក្តី ។
នៅពេលមាតាឬបិតា
រលត់សង្ខារលាលោកិយ
កូនធ្វើបុណ្យតាមប្រពៃណី
បុត្រាបុត្រីត្រូវចងចាំ ។



www.elibraryofcambodia.org

## សំណួរ

១. តើពាក្យ "កតញ្ញូ" មានន័យដូចម្ដេច ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។
២. តើកូនត្រូវមានកតញ្ញូប៉ុន្មានប្រការចំពោះម្ដាយឪពុក ?
៣. ចូរពន្យល់អត្ថន័យនៃប្រការនីមួយៗ នៅក្នុងកំណាព្យនេះ ។
៤. តើអ្នកបានធ្វើអ្វីខ្លះដើម្បីសងគុណម្ដាយឪពុកអ្នក ?
៥. តើអត្ថបទកំណាព្យនេះ និយាយអំពីអ្វី?
៦. តើអត្ថបទកំណាព្យនេះ មានគំនិតអប់រំដូចម្ដេច ?
៧. តើកំណាព្យនេះមានប៉ុន្មានវគ្គ ? តើក្នុងមួយវគ្គមានប៉ុន្មានឃ្លា ?
៨. ចូរប្រាប់ពាក្យចួនក្នុងវគ្គនិងពាក្យចួនឆ្លងវគ្គនៅក្នុងកំណាព្យខាងលើ ។

## លំហាត់

ក. ចូរប្រើវចនានុក្រមដើម្បីពន្យល់ន័យពាក្យ ៖

ធុរៈ ស្រាន្ត ពង្ស ញាតិ កេរ្តិ៍ វន្ទា សន្តាន សង្ខារ ឧទ្ទិស ។

ខ. ចូរគូសភ្ជាប់ពាក្យដែលមានន័យដូចគ្នាឱ្យបានត្រឹមត្រូវ ។

| | |
|---|---|
| ១. វាចា | ក. ម្ដាយ |
| ២. សព | ខ. សម្ដី |
| ៣. បុត្រ | គ. ឪពុក |
| ៤. វន្ទា | ឃ. កូន |
| ៥. មាតា | ង. ខ្មោច |
| ៦. បិតា | ច. សំពះ ។ |



www.elibraryofcambodia.org

## សំណេរ

ក. ចូរតែងល្បះដោយប្រើពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

គុណ ៖ .................................................................................................. ។

ថ្នាក់ ៖ .................................................................................................. ។

សងគុណ ៖ .................................................................................................. ។

ស្រឡាញ់ ៖ .................................................................................................. ។

ខ. ចូរតែងល្បះទាក់ទងគ្នាតាមរូបភាពនេះឱ្យបាន៥ ល្បះ ។



គ. ចូរអ្នកសរសេរតែងសេចក្តីពណ៌នាអំពីម្តាយរបស់អ្នកដោយប្រើគម្រោងខាងក្រោម ៖

១. សេចក្តីផ្តើម

- ឈ្មោះ អាយុ មុខរបរ
- ទីកន្លែងរស់នៅ ។

២. តួសេចក្តី

- រូបសម្បត្តិ ៖ រូបរាង សម្បុរ ទម្រង់មុខ សក់ ភ្នែក ច្រមុះ មាត់ ដៃជើង ...
- ចរិយាសម្បត្តិ ៖ ស្លូត កាច ព្យាយាម យោគយល់ អធ្យាស្រ័យ ...
- សកម្មភាព ៖ ទំនាក់ទំនង សាមគ្គីភាព ការថែរក្សាបីបាច់កូន ... ។

៣. សេចក្តីបញ្ចប់

ចំណាប់អារម្មណ៍ចំពោះម្តាយអ្នក ។



www.elibraryofcambodia.org

## ការកត់ត្រាគំនិតសំខាន់ៗនៅក្នុងកំណាព្យ

ពេលអ្នកស្ដាប់ ឬអានអត្ថបទអ្វីមួយ អ្នកគួរកត់ត្រាចំណុចសំខាន់ៗព្រោះធ្វើឱ្យអ្នកងាយចងចាំ ងាយយល់អត្ថបទនោះ ។ ការកត់ត្រានេះ មិនទាមទារឱ្យអ្នកសរសេរជាល្បះពេញលេញទេ គឺសរសេរតែពាក្យ ឬកន្សោមពាក្យសំខាន់ៗប៉ុណ្ណោះ ។

ចូរអានកំណាព្យខាងក្រោម ដោយកត់សម្គាល់គំនិតសំខាន់ៗ ។

(បទកាកគតិ)

ត្រូវធ្វើបុណ្យខ្មើត ម៉ែឪស៊ីកើត កំពុងស្រែកឃ្លាន
ម៉ែឪរស់នៅ កូនត្រូវធ្វើទាន បំបាត់ក្ដីឃ្លាន
ហៅធ្វើបុណ្យខ្មើត ។

ហៅបុណ្យខែភ្លឺ កុំចាំគាត់ឈឺ ពិសាលែងកើត
ជូនគាត់ពេលជា ហៅថាបុណ្យខ្មើត គាត់ពិសាកើត
បានជាងរនោច ។

លុះបាត់ជីវិត បុណ្យខែងងឹត ដូចថ្ងៃដប់រោច
កូនចៅទាំងឡាយ យកបាយឱ្យខ្មោច ម៉ែឥតប្រយោជន៍
ខ្មោចណាចេះស៊ី ។

(ដកស្រង់ចេញពី ច្បាប់គោរពមាតាបិតា របស់លោក ម៉ី ចុង)

គំនិតសំខាន់ៗនៅក្នុងកំណាព្យនេះមាន ៖

- ត្រូវធ្វើបុណ្យខាន់ខែភ្លឺ ឬខ្មើត : ម៉ែឪនៅរស់ ម៉ែឪពិសាកើត កំពុងស្រេកឃ្លាន កូនត្រូវជូនចំណីអាហារ កុំចាំគាត់ឈឺពិសាលែងកើត ។
- ធ្វើបុណ្យខែងងឹត : ម៉ែឪបាត់ជីវិត យកបាយឱ្យខ្មោចស៊ី ម៉ែឪឥតបានប្រយោជន៍ ។

> ការកត់ត្រាគំនិតសំខាន់ៗ គឺការកត់ពាក្យ កន្សោមពាក្យ ឃ្លាដែលប្រាប់គំនិតសំខាន់ៗក្នុងអត្ថបទ ។

## លំហាត់

ចូរអាននិងសូត្រកំណាព្យខាងក្រោម រួចកត់ត្រាគំនិតសំខាន់ៗ ។

### សន្តានចិត្តរបស់អ្នកម្តាយ

(បទព្រហ្មគីតិ)



ពេលកូនមកចាប់ផ្ទៃ ក្នុងហឫទ័យម្តាយសប្បាយ
ម៉ែតែងតែខ្វល់ខ្វាយ រកឧបាយថែរក្សា ។
ធ្វើអ្វីតែងប្រយ័ត្ន មិនឱ្យភ្លាត់ខ្លាចបំពារ
ឱ្យកូនបានសុខជា ម្តាយបានគាំពារស្ងួន ។
ស៊ូនឿយព្រោះថ្លើមថ្លៃ រង់ចាំថ្ងៃប្រសូតខ្លួន
បានឃើញមុខកូនស្ងួន ថ្នមថៃថួនព្រោះស្រឡាញ់ ។



www.elibraryofcambodia.org

# ៦ ការគោរពលោកគ្រូ អ្នកគ្រូ



## សំណួរ

១. តើសិស្សត្រូវធ្វើអ្វីខ្លះ ចំពោះលោកគ្រូ អ្នកគ្រូ ?

២. ហេតុអ្វីបានជាសិស្សត្រូវគោរពលោកគ្រូ អ្នកគ្រូ ?

៣. តើអត្ថបទកំណាព្យនេះ មានគំនិតអប់រំដូចម្ដេច ?

## លំហាត់

**ចូរគូសសញ្ញា ✓ នៅមុខល្បះដែលជាគំនិតសំខាន់ៗនៅក្នុងអត្ថបទកំណាព្យ ។**

- ☐ ១. សិស្សក្រោកឈរនិងប្រកាន់ការស្ងៀមស្ងាត់ពេលគ្រូមកដល់ ។
- ☐ ២. សិស្សត្រូវធ្វើព្រាប់តាមពុតគ្រូ ។
- ☐ ៣. សិស្សធ្វើកិច្ចការដែលគ្រូដាក់ឱ្យដោយផ្ចិតផ្ចង់ ។
- ☐ ៤. សិស្សយកចិត្តទុកដាក់ស្ដាប់គ្រូពន្យល់ ។
- ☐ ៥. សិស្សត្រូវមានស្មារតីសាមគ្គីភាព ។
- ☐ ៦. សិស្សត្រូវចូលរួមរំលែកទុក្ខរបស់គ្រូ ពេលគាត់មានធុរៈ ។



www.elibraryofcambodia.org

## គុណនាមចំនួន

គុណនាម គឺជាប្រភេទពាក្យម្យ៉ាងដែលប្រាប់លក្ខណៈរបស់នាម ។ អ្នកធ្លាប់បានសិក្សារួចមកហើយអំពីប្រភេទផ្សេងៗនៃគុណនាម ។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីគុណនាមចំនួន ។ គុណនាមចំនួនមានពីរយ៉ាង គឺគុណនាមចំនួនរាប់ និងគុណនាមចំនួនរៀប ។



ក. គុណនាមចំនួនរាប់

១. គ្រួសារសុនាមានមនុស្សចំនួនប្រាំមួយនាក់ ។

២. សុនាមានបងប្អូនបង្កើតចំនួនបួននាក់ ។

៣. ពួកគេកំពុងហូបម្ហូបបីមុខ គឺសម្លទឹកមួយមុខ ឆាមួយមុខ និងត្រីអាំងមួយមុខ ។

៤. គេឃើញមានចានបាយ និងចានម្ហូបទាំងអស់ប្រាំបួន ។

៥. សុនាចិញ្ចឹមឆ្មាមួយ ។

ពាក្យ " ប្រាំមួយ បួន បី មួយ និងប្រាំបួន" ជាចំនួនរាប់ ។

គុណនាមចំនួនរាប់ គឺជាគុណនាមប្រាប់ចំនួនមនុស្ស សត្វ វត្ថុ ដែលគេរាប់ ។



www.elibraryofcambodia.org

## ខ. គុណនាមចំនួនរៀប

១. បងប្រុសសុខាជាកូនទីមួយនៅក្នុងគ្រួសារ ។ គេរៀននៅថ្នាក់ទីប្រាំបី ។

២. សុខាជាកូនទីបី ។ នាងរៀននៅថ្នាក់ទីប្រាំមួយ ។

៣. ប្អូនស្រីសុខាជាកូនទីបួន ។ គេរៀនបានលេខ២ ។

៤. គ្រួសារនេះ ហូបបាយថ្ងៃត្រង់នៅម៉ោងដប់មួយគត់ ។

ពាក្យ : ទីមួយ ទីប្រាំបី ទីបី ទីប្រាំមួយ ទីបួន លេខ២ ម៉ោងដប់មួយជាចំនួនរៀប ។

> គុណនាមចំនួនរៀបគឺជាគុណនាមប្រាប់ទី លំដាប់ ជាន់ ឬថ្នាក់ ដែលគេរៀប ។

## លំហាត់

ក. ចូរស្រង់គុណនាមចំនួនរាប់ និងគុណនាមចំនួនរៀបពីក្នុងប្រអប់ទៅដាក់ក្នុងតារាងខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | | |
|---|---|---|---|---|---|---|
| ទីប្រាំ | ដប់ពីរ | ថ្នាក់ទី៣ | ជាន់ទីពីរ | មួយឡូ | បួនរយ | បីពាន់ |
| ទីហាសិប | ម៉ោងប្រាំមួយ | ប្រាំមួយ | សាមសិប | យប់ទីបី | ពីរម៉ឺន | |

| គុណនាមចំនួនរាប់ | គុណនាមចំនួនរៀប |
|---|---|
| ដប់ពីរ .............................. | ទីប្រាំ .............................. |

ខ. ចូរបង្កើតឃ្លាដោយប្រើគុណនាមចំនួនរាប់ និងគុណនាមចំនួនរៀបខាងក្រោមឱ្យបានត្រឹមត្រូវ ។

បី ទីដប់ លេខបួន ជាន់ទី២ ម៉ោងមួយ ។



www.elibraryofcambodia.org

# រឿង បងប្រុស



និតនិងនួនជាបងប្អូនបង្កើតនឹងគ្នា ។ តាំងពីអ្នកមានគុណបានចែកឋានទៅ ជីវភាពគ្រួសារពួកគេជួបការលំបាកយ៉ាងខ្លាំង ។ និតជាបងបានសម្រេចចិត្តផ្អាកការរៀនសូត្រមួយរយៈដោយទុកឱ្យប្អូនបានសិក្សាបន្តទៀត ។ នួនខំរៀនណាស់មិនឱ្យបងខកចិត្តឡើយ ។ឯនិតវិញ ពេលទំនេរពីការងារស្រែចម្ការ គេបានចូលសិក្សានៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ ។

ឆ្នាំនេះ នួនរៀននៅថ្នាក់ទី១២ ហើយបានប្រឡងជាប់ដូចប្រាថ្នា ។ ថ្ងៃមួយ នួនចង់ទៅរកការងារធ្វើ ដើម្បីជួយសម្រាលបន្ទុកបង តែនិតមិនយល់ព្រម ។ នួនសួរបង ៖

" តើយើងបានប្រាក់ពីណា ? " ។

និតឆ្លើយ ៖ " ឯងកុំបារម្ភ ! ទុកឱ្យបងជាអ្នកដោះស្រាយ " ។

រាត្រីនោះ និតនិទ្រាមិនលក់សោះ ព្រោះខ្លួនមិនដឹងទៅប្រកបរបរអ្វីដើម្បីរកបានប្រាក់ឱ្យប្អូនរៀននោះទេ ។ ពីមួយថ្ងៃទៅមួយថ្ងៃ និតចេះតែជញ្ជឹងគិតរកមុខរបរផ្សេងៗ តែនឹកមិនឃើញសោះ ។ ចំណែកនួនអាណិតបងខ្លាំងណាស់ ។ គេតាំងចិត្តថានឹងខិតខំរៀនសូត្រ ដើម្បីបានការងារធ្វើចិញ្ចឹមបងគេវិញ ។

ថ្ងៃមួយ និតនិងអ្នកភូមិខ្លះបាននាំគ្នាទៅខ្ចីប្រាក់ឥណទានពីធនាគារភូមិ យកមកធ្វើជាដើមទុនក្នុងការចិញ្ចឹមជ្រូកនិងត្រី ។ ជាលើកដំបូង និតបានត្រឹមតែរួចដើមប៉ុណ្ណោះ ។ ក្រោយមក និតបានរៀនបច្ចេកទេសចិញ្ចឹមសត្វពីមជ្ឈមណ្ឌលសិក្សាសហគមន៍ ។ ចាប់ពីពេលនោះមក និតចេះជំនាញចិញ្ចឹមសត្វច្បាស់លាស់ ។ និតអាចរកប្រាក់ឧបត្ថម្ភការសិក្សារបស់នួនដោយមិនជួបការលំបាកដូចមុនទៀតឡើយ ។



www.elibraryofcambodia.org

ក្រោយពីបញ្ចប់ការសិក្សា ខ្លួនបានចូលបម្រើការងារក្នុងក្រុមហ៊ុនមួយ នៅរាជធានីភ្នំពេញ ។ ខ្លួនសន្សំប្រាក់ខែបានមួយចំនួន ។ គេបានយកប្រាក់ទាំងនោះទៅប្រគល់ជូនបងទាំងអស់ ដើម្បីឱ្យបងបានរៀបអាពាហ៍ពិពាហ៍ ។ ចាប់ពីពេលនោះមក គ្រួសារនេះរស់នៅជាមួយគ្នាប្រកបដោយសុភមង្គល ។

**សំណួរ**

១. តើនិតនិងខ្លួនត្រូវជាអ្វីនឹងគ្នា?
២. តើនិតប្រើមធ្យោបាយអ្វី ដើម្បីឱ្យខ្លួនបានបន្តការសិក្សា ?
៣. ហេតុអ្វីបានជានិតតស៊ូចិញ្ចឹមប្អូនឱ្យបានរៀនសូត្រ ?
៤. តើអ្នកពេញចិត្តតួអង្គនិតដែរ ឬទេ ? ហេតុអ្វី ?
៥. តើរឿងនេះ មានគំនិតអប់រំដូចម្ដេច ?

**លំហាត់**

ក. **ចូរប្រើវចនានុក្រមដើម្បីពន្យល់ន័យរបស់ពាក្យ ៖**

បច្ចេកទេស ឥណទាន ឧបត្ថម្ភ ធនាគារ សហគមន៍ ។

ខ. **ចូររកពាក្យន័យដូចមកជំនួសពាក្យដែលមានគំនូសពីក្រោមក្នុងល្បះនីមួយៗ ។**

១. និតបានសម្រេចចិត្តឈប់រៀន ដោយទុកឱ្យខ្លួនបានសិក្សាបន្តទៀតឡើយ ។
២. រាត្រីនេះនិតនិទ្រាមិនលក់សោះ ។
៣. និតអាចរកប្រាក់ឧបត្ថម្ភខ្លួន ដោយមិនមានការលំបាកដូចមុនទៀត ។
៤. និតបានប្រគល់ប្រាក់ជូនបងទាំងអស់ ដើម្បីឱ្យបងបានរៀបអាពាហ៍ពិពាហ៍ ។

## ការតែងរឿងខ្លី

**ចូរអ្នកសរសេររឿងខ្លីមួយ រៀបរាប់អំពីគុណរបស់បងប្រុស ឬ បងស្រីអ្នកដែលបានធ្វើចំពោះអ្នក ។**



www.elibraryofcambodia.org

## ការពណ៌នាអំពីអ្នកមានគុណ

ស្រីណែតឃើញឪពុករៀបនំចំណី ផ្លែឈើ នាងឆ្ងល់ណាស់ ក៏សួរឪពុក ។ ចូរអាន ការសន្ទនារវាងស្រីណែត និងឪពុកនាងខាងក្រោម ៖

ស្រីណែត : លោកប៉ា ! ព្រឹកនេះកូនឃើញប៉ារៀបចំត្រកដាក់ផ្លែឈើ នំចំណី និង ទឹកដោះគោ តាំងពីព្រលឹម ។ តើប៉ាបម្រុងអញ្ជើញទៅណា ?

ឪពុក : អូ ! កូនស្រី ប៉ាទៅសួរសុខទុក្ខលោកយាយសួននៅឯស្រុក ។ ប៉ានឹកគាត់ ណាស់ ។

ស្រីណែត : តើលោកយាយសួនជាអ្នកណា ? កូនឃើញប៉ាយកចិត្តទុកដាក់នឹងគាត់ ណាស់ ។

ឪពុក : គាត់ជាម្ដាយមីងរបស់ប៉ា ហើយមានគុណលើប៉ាខ្លាំងណាស់ ។ កាលប៉ា នៅរៀន គ្រួសារប៉ាក្រីក្រ ។ លោកយាយបានយកប៉ាទៅនៅជាមួយ ចិញ្ចឹមបាយទឹក ហើយឧបត្ថម្ភប្រាក់កាសឱ្យប៉ារៀនសូត្រ រហូតប៉ាបាន ការងារធ្វើសព្វថ្ងៃនេះ ។ ហេតុនេះហើយទើបប៉ាមិនភ្លេចគុណគាត់ ។

ស្រីណែត : កូនរំភើបចិត្តណាស់ ។ ក្រៅពីលោកយាយបង្កើត កូននៅមានលោក យាយសួនម្នាក់ទៀត ។ លោកប៉ា! កូនសូមបួងសួងឱ្យពួកគាត់មានអាយុ វែង ។

### សំណួរ

១. តើស្រីណែតសួរឪពុកនាងអំពីរឿងអ្វីខ្លះ ?

២. តើឪពុកនាងឆ្លើយដូចម្ដេចខ្លះ ?

### លំហាត់

ចូររៀបគ្នាជាក្រុមតូចៗ រួចរៀបរាប់ពីអ្នកមានគុណអ្នក ប្រាប់សមាជិកក្រុមអ្នក ។



www.elibraryofcambodia.org

## ការតែងកំណាព្យ

ចូរអានកំណាព្យបទពាក្យប្រាំពីរខាងក្រោម ដោយកត់សម្គាល់ទីតាំងពាក្យចួនក្នុងវគ្គ និងឆ្លងវគ្គ ។

១ ២ ៣ ៤ ៥ ៦ ៧ ១ ២ ៣ ៤ ៥ ៦ ៧
វគ្គទី១ : ខ្ញុំ សូម វ ន្ទា ចំ ពោះ គុណា ធំ ហើយ សែន ធ្ងន់ មក លើ ខ្ញុំ
១ ២ ៣ ៤ ៥ ៦ ៧ ១ ២ ៣ ៤ ៥ ៦ ៧
មាន ឪ ពុក ម្ដាយ ដ៏ ឧ ត្ដម មីង ពូ បង អំ ក្រុម គ្រួ សារ ។

វគ្គទី២ : លោក គ្រូ អ្នក គ្រូ ផ្ដល់ ចំ ណេះ ឱ្យ ខ្ញុំ បាន ចេះ មាន ប្រា ជ្ញា
បួង សួង ឱ្យ លោក ជួប សុ ខា កើត ជាតិ ណា ៗ សូម ជួប ទៀត ។

### សំណួរ

១. តើកំណាព្យខាងលើមានប៉ុន្មានវគ្គ ?
២. តើពីត្រឹមណាដល់ត្រឹមណាដែលហៅថា ១ វគ្គ ?
៣. តើកំណាព្យបទពាក្យប្រាំពីរ ក្នុងមួយវគ្គមានប៉ុន្មានឃ្លា ?
៤. តើក្នុងមួយឃ្លាមានប៉ុន្មានព្យាង្គ ?
៥. តើព្យាង្គណាខ្លះចួនគ្នានៅក្នុងវគ្គ ?
៦. តើព្យាង្គណាខ្លះចួនឆ្លងវគ្គ ? ( ឆ្លងពីវគ្គទី ១ មកវគ្គទី ២)

### លំហាត់

ចូរពិនិត្យមើលទីតាំងពាក្យចួននៅក្នុងកំណាព្យបទពាក្យប្រាំពីរខាងលើ រួចតែងកំណាព្យបទពាក្យប្រាំពីរចំនួនបីវគ្គនិយាយពីប្រធានបទណាមួយដែលអ្នកពេញចិត្ត ។



www.elibraryofcambodia.org

មេរៀនទី

# ២ ក្តីសង្ឃឹមរបស់កុមារ




កុមារនិងយុវជន មានភារកិច្ចសំខាន់ក្នុងការជួយទ្រទ្រង់ប្រទេសជាតិឱ្យមានការរីកចម្រើន ។ ដើម្បីឱ្យកុមារអាចសម្រេចភារកិច្ចនេះបានល្អ លុះត្រាតែមាតាបិតា អាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងសហគមន៍ផ្តល់សិទ្ធិពេញលេញដល់កុមារ ការពារកុមារ និងមិនរំលោភបំពានលើសិទ្ធិរបស់ពួកគេ ។

តើកុមារមានសិទ្ធិអ្វីខ្លះ ? តើអ្វីខ្លះជាការរំលោភសិទ្ធិកុមារ ?



www.elibraryofcambodia.org

# ការសង្ខេបរឿង

នៅពេលណាអ្នកចង់និយាយ ឬសរសេររឿងនិទានណាមួយប្រាប់អ្នកដទៃ អ្នកមិនអាចរៀបរាប់លម្អិតគ្រប់ចំណុចបានទេ អ្នកត្រូវតែសង្ខេបរឿងនោះ ដើម្បីឱ្យអ្នកស្ដាប់ ឬអ្នកអានងាយចងចាំ ។

សង្ខេបរឿង មានន័យថា និយាយ ឬសរសេរបំព្រួញរឿងឱ្យខ្លី ដោយប្រើប្រាស់ពាក្យពេចន៍របស់ខ្លួន ដើម្បីឱ្យគេស្ដាប់បាន និងយល់ខ្លឹមសារសំខាន់ៗនៃរឿងនោះ ។

ដើម្បីសង្ខេបរឿង អ្នកត្រូវអនុវត្តតាមជំហានបន្តបន្ទាប់ខាងក្រោម ៖

១. អានរឿងទាំងមូល និងស្វែងយល់ខ្លឹមសារឱ្យបានច្បាស់លាស់ជាមុន

២. ស្រង់ព្រឹត្តិការណ៍សំខាន់ ឬខ្លឹមសារសំខាន់របស់រឿង

៣. ប្រមូលផ្ដុំព្រឹត្តិការណ៍បន្ទាប់បន្សំ ដែលមានក្នុងព្រឹត្តិការណ៍សំខាន់នីមួយៗ

៤. រៀបព្រឹត្តិការណ៍តាមលំដាប់មុនក្រោយ

៥. និយាយ ឬសរសេររឿងនោះឡើងវិញ ដោយផ្អែកលើគម្រោងដែលបានធ្វើរួច ។ អ្នកត្រូវប្រើកន្សោមពាក្យ ឬល្បះភ្ជាប់សេចក្ដី ដើម្បីភ្ជាប់ព្រឹត្តិការណ៍មួយទៅព្រឹត្តិការណ៍មួយទៀត ឱ្យជាប់រលីកតាំងពីដើមរហូតដល់ចប់ ។

**ចូរអ្នកអានរឿងខាងក្រោម រួចពិនិត្យមើលរបៀបសរសេរ ។**

## រឿង ព្រាហ្មណ៍និងស្កា

មានរឿងតំណាលថា មានព្រាហ្មណ៍ម្នាក់និងភរិយាបានចិញ្ចឹមសត្វស្កាមួយ ។ ព្រាហ្មណ៍ស្រឡាញ់ស្កានោះដូចកូនបង្កើតដែរ ។

ថ្ងៃមួយ ព្រាហ្មណ៍និងភរិយាមានធុរៈចេញទៅក្រៅ ហើយទុកកូនតូចឱ្យស្កាថែរក្សា ។ ពេលព្រាហ្មណ៍និងភរិយាចេញផុតទៅ មានពស់វែកមួយលូនចូលមកជិតកូននោះ ។ ស្កាឃើញពស់ជាសត្រូវពីកំណើតមកដល់ ក៏ស្ទុះទៅខាំពស់នោះដាច់ជាពីរ បីកំណាត់ភ្លាម ។ ក្រោយមក ស្កាក្រឡេកមើលទៅឃើញព្រាហ្មណ៍កំពុងដើរចូលមកត្រេកអរណាស់ ទាំងមុខមាត់ដៃជើងប្រឡាក់ឈាមក្រហមច្រាលនៅឡើយ ក៏រត់ទៅននៀល



www.elibraryofcambodia.org

នៅក្បែរជើងព្រាហ្មណ៍ ដើម្បីសម្តែងអាការត្រេកអរដែលបានបម្រើម្ចាស់ដោយប្រពៃ ។ ឯព្រាហ្មណ៍ឃើញឈាមនៅមុខ មាត់ ជើងស្វាត្រហាមប្រាលដូច្នោះ គិតំណាត់ក្នុងចិត្តឥតពិចារណា ៖ " ស្វានេះស៊ីកូនអាត្មាអញហើយ " ។ ព្រាហ្មណ៍លើកដំបងសំពងស្វានោះងាប់ទៅ ។

ភ្លាមនោះ ព្រាហ្មណ៍ក៏ចូលទៅមើលកូន ឃើញកូនសុខសប្បាយធម្មតា ហើយឃើញពស់ដាច់ជាពីរបីកំណាត់ នៅរាត់រាយក្បែរអង្រឹងកូន ទើបដឹងថាស្វាបានជួយជីវិតកូនគាត់ឱ្យផុតពីពស់ចឹក ។ ព្រាហ្មណ៍មានចិត្តសោកស្តាយក្រៃលែង ។

(សម្រួលពីស្រីហិតោបទេសភាគ៤)

## រឿង ព្រាហ្មណ៍និងស្វា

កាលអាកាស ៖

- កាល ឬពេលវេលា : ថ្ងៃមួយ ពេលព្រាហ្មណ៍ និងភរិយាចេញផុត ក្រោយមកព្រាហ្មណ៍ចូលទៅមើលកូន ។
- ទីកន្លែង : ផ្ទះព្រាហ្មណ៍ ។

តួអង្គ ៖ ព្រាហ្មណ៍ ភរិយាព្រាហ្មណ៍ ស្វា ពស់ កូនតូច ។

ព្រឹត្តិការណ៍ ៖

- ព្រាហ្មណ៍និងភរិយាចិញ្ចឹមស្វា
- ព្រាហ្មណ៍និងភរិយាចេញទៅក្រៅ ទុកកូនតូចឱ្យស្វាថែរក្សា
- ពស់វែកមួយលូនមកជិតកូនតូច
- ស្វាស្ទុះទៅខាំពស់ដាច់ជាពីរបីកំណាត់
- ព្រាហ្មណ៍ត្រឡប់មកវិញ ឃើញស្វាប្រឡាក់សុទ្ធតែឈាម
- ព្រាហ្មណ៍វាយស្វាងាប់
- ព្រាហ្មណ៍ឃើញកូនសុខសប្បាយក៏នឹកស្តាយស្វា ។



www.elibraryofcambodia.org

ចូរអានសេចក្ដីសង្ខេបរឿង " ព្រាហ្មណ៍និងស្កា " ខាងក្រោម ៖

មានតំណាលថា មានព្រាហ្មណ៍និងប្រពន្ធបានចេញទៅក្រៅ ទុកកូនតូចឱ្យនៅជាមួយស្កា ។ ពេលនោះ មានពស់វែកមួយលូនមកជិតកូននោះ ។ ស្កាឃើញពស់ក៏ស្ទុះទៅខាំពស់នោះដាច់ជាពីរបីកំណាត់ ។ ពេលព្រាហ្មណ៍ត្រឡប់មកវិញ ស្កាក៏រត់ទៅឆ្កៀលក្បែរជើងគាត់ដោយសេចក្ដីត្រេកអរ ។ ព្រាហ្មណ៍ឃើញស្កាមានមុខ មាត់ ដៃ ជើងប្រឡាក់ឈាម គិតស្មានថា ស្កាខាំកូនខ្លួន ក៏យកដំបងវាយស្កាងាប់ភ្លាម ។ ក្រោយមកពេលព្រាហ្មណ៍ឃើញកូនសុខសប្បាយ គាត់នឹកស្ដាយស្កាដែលជួយការពារកូនគាត់ឱ្យរួចផុតពីគ្រោះថ្នាក់ ។

> សង្ខេបរឿង គឺនិយាយ ឬសរសេររឿងឡើងវិញ តាមលំដាប់លំដោយព្រឹត្តិការណ៍សំខាន់ៗរបស់រឿងដោយប្រើសម្ដីផ្ទាល់ខ្លួន ។

លំហាត់

ចូរអានរឿង " ក្មេងស្រីបីនាក់ " ហើយសង្ខេបរឿងនេះ ។

ស្ត្រីមេម៉ាយម្នាក់មានកូនស្រីបីនាក់ ។ កូនស្រីបងចូលចិត្តដើរលេងជាមួយមិត្តភក្ដិ ។ កូនស្រីបន្ទាប់មិនសូវចូលចិត្តការរៀនសូត្រទេ ។ រីឯកូនស្រីពៅ ជាក្មេងស្លូតបូតចេះគិតគូរដល់គ្រួសារ និងខិតខំរៀនសូត្រ ។

ថ្ងៃមួយ ពេលម្ដាយមិននៅ កូនទី១ និងទី២ បានឈ្លោះប្រកែកគ្នា ទោះបីប្អូនពៅឃាត់យ៉ាងណាក៏មិនស្ដាប់ ។ ពេលបានដឹងរឿង ម្ដាយក៏ហៅកូនទាំងបីនាក់មកជួបជុំគ្នា ។ ម្ដាយប្រាប់កូនម្នាក់ៗឱ្យរៀបរាប់អំពីការងារមានប្រយោជន៍ដែលគេបានធ្វើនៅថ្ងៃនេះ ។ ម្ដាយបានប្រាប់កូនថា គាត់នឹងឱ្យកូនបងទាំងពីរទៅនៅជាមួយបងប្អូននៅឯទីក្រុងធ្វើការជាមួយគេ ហើយទុកកូនពៅឱ្យនៅជាមួយ ព្រោះនាងខំរៀននិងជួយការងារផ្ទះ ។ កូនស្រីបងទាំងពីរដឹងខ្លួនខុស ក៏សន្យាថានឹងកែខ្លួន ហើយសុំឱ្យនាងបានរៀនតទៅទៀត ។ ម្ដាយក៏យល់ព្រម ។



www.elibraryofcambodia.org

# រឿង បងប្អូនពីរនាក់



គ្រួសារមួយមានកូនពីរនាក់ ។ កូនស្រីច្បងឈ្មោះ នាគ កូនប្រុសប្អូនឈ្មោះ ណាត ។ ណាត ច្រើនតែច្រណែននឹងបងស្រីខ្លួន ។ ចំណែក នាគវិញមិនដែលប្រកាន់នឹងប្អូនទេ ។ នាងតែងតែសម្របចិត្តប្អូនជានិច្ច ។

ឪពុកម្ដាយក្មេងទាំងពីរ មានចិត្តអាណិតស្រឡាញ់កូនស្មើគ្នា ។ ពេលគាត់ទៅណា គាត់យកកូនទាំងពីរទៅជាមួយជាដរាប ។ គាត់ផ្គត់ផ្គង់ចំណីអាហារ សម្លៀកបំពាក់កូនទាំងពីរមិនឱ្យលើសខ្វះគ្នាឡើយ ។ គាត់មិនដឹងថាត្រូវធ្វើដូចម្ដេចទេ ដើម្បីឱ្យ ណាត យល់ចិត្តបងស្រី និងចេះស្រឡាញ់បងស្រីខ្លួន ។ ពួកគាត់តែងតែខ្វល់ខ្វាយនឹងរឿង ណាត ជានិច្ច ។

មានថ្ងៃមួយ ពួកគាត់បានសាកល្បងដោយប្រើមធ្យោបាយមួយ ។ គាត់ដឹងថា ក្មេងប្រុសចូលចិត្តលេងកូនឡាន ។ ពួកគាត់នាំគ្នាទៅផ្សារ ទិញកូនឡានជ័រមួយ និងសៀវភៅរូបភាពអំពីឡានតូច ធំមួយសម្រាប់ ។ គាត់បានយករបស់ទាំងនោះទៅឱ្យនាគ ហើយប្រាប់ ៖ " កូនឯងទុករបស់នេះកុំឱ្យប្អូនឃើញ ។ ដំបូងកូនយកកូនឡាននេះឱ្យទៅប្អូនដោយប្រាប់ថា មិត្តភក្ដិកូនឱ្យកូន ។ ថ្ងៃក្រោយ កូនឱ្យសៀវភៅមួយសម្រាប់នេះទៀត" ។ នាគទទួលយល់ព្រមធ្វើតាមម្ដាយ ។



www.elibraryofcambodia.org

ដល់ពេលរសៀល នាគបានយកកូនឡានជ័រមកហុចឱ្យណាគព្រមទាំងនិយាយ ៖

- ណាគ ! មកនេះ បងឱ្យកូនឡានមួយ ។

ណាគនិយាយដោយមើលមុខបង ៖

- តើបងបានកូនឡានហ្នឹងមកពីណា ? ហេតុអ្វីបានជាបងមិនទុកលេងខ្លួនឯង ?

នាគឆ្លើយ ៖

- មិត្តភក្តិបងឱ្យបង តែបងមិនលេងទេ បងឱ្យវាទៅអូនវិញ ព្រោះអូនស្រឡាញ់ឡានណាស់ ។

ណាគទទួលយកឡានពីបងភ្លាមក៏រត់ចេញមកក្រៅ យកទៅលេងមួយរំពេច ។

មួយសប្តាហ៍ក្រោយមក ពេលឃើញប្អូននៅជិត នាគធ្វើជាយកសៀវភៅរូបភាពឡានមកបើកមើល ។ ណាគចេះតែលួចតាមមើល ដោយឃើញរូបឡានប្លែកៗជាច្រើន ។ វាចង់បានណាស់ តែមិនហ៊ានសុំ ។ នាគដឹងចិត្តប្អូន ក៏បើកសៀវភៅបង្ហាញរូបភាពមួយចំនួន រួចសួរ ៖

- អូនឯងចង់បានសៀវភៅនេះ ឬទេ ? បើចង់បានបងឱ្យ ។

ណាគងក់ក្បាល ព្រមទាំងសួរបង ៖

- ម្តេចបងមិនទុកវាមើល ?

នាគមើលមុខប្អូនដោយញញឹម ហើយនិយាយដោយម៉ឺងម៉ាត់ ៖

- អត់ទេ ! បងឱ្យអូនឯងមើលវិញ ។

ថាហើយ នាងក៏ហុចសៀវភៅនោះទៅប្អូន ហើយណែនាំ ៖

- បើកវាថ្នមៗណា៎ កុំឱ្យវាដាច់រហែក ។ ថ្ងៃក្រោយ បើបងបានអ្វីប្លែក បងនឹងឱ្យអូនទៀត ។

ណាគញញឹម ហើយនិយាយទៅកាន់បង ៖

- អរគុណបង ! ខ្ញុំនឹងថែវាឱ្យបានល្អ ។



www.elibraryofcambodia.org

ចាប់ពីថ្ងៃនោះមក ណាតតែងតែទៅជិតនាត ។ ជួនកាលពួកគេនិយាយ ឬលេងជាមួយគ្នាយ៉ាងសប្បាយ ។ មាតាបិតា ក្មេងទាំងពីរសប្បាយចិត្តណាស់ ។

## សំណួរ

១. តើណាតច្រណែននឹងអ្នកណា ?

២. តើនាតស្អប់ណាត ឬទេ ?

៣. តើឪពុកម្ដាយមានអារម្មណ៍ដូចម្ដេច ពេលឃើញកូនមិនស្រឡាញ់គ្នា ?

៤. តើឪពុកម្ដាយនាតធ្វើដូចម្ដេច ដើម្បីឱ្យកូនចេះស្រឡាញ់គ្នា ?

៥. តើមធ្យោបាយនោះបានសម្រេចដែរ ឬទេ ?

៦. តើណាតធ្វើដូចម្ដេចនៅចុងបញ្ចប់ ?

៧. តើនាតជាក្មេងដូចម្ដេច ?

៨. តើអ្នកចូលចិត្តតួអង្គណាខ្លះនៅក្នុងរឿងនេះ ? ហេតុអ្វី ?

## លំហាត់

ក. ចូររកពាក្យផ្ទុយនឹងពាក្យ ៖

កូនច្បង ខ្វល់ចិត្ត ស្រឡាញ់ ប្លែកៗ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់មកជំនួសពាក្យដែលមានគំនូសពីក្រោម ។

| អាទិត្យ | ប្រាកដប្រជា | ទំនុកបម្រុង | ម្ដាយឪពុក |
|---|---|---|---|

១. ឪពុកនាត <u>ផ្គត់ផ្គង់</u> ចំណីអាហារ សម្លៀកបំពាក់កូនមិនឱ្យលើសខ្វះគ្នាឡើយ ។

២. មួយ <u>សប្ដាហ៍</u> ក្រោយមក ពេលឃើញប្អូននៅជិត នាតធ្វើជាយកសៀវភៅរូបភាពមកបើកមើល ។

៣. នាតមើលមុខប្អូន ហើយនិយាយដោយ<u>ម៉ឺងម៉ាត់</u> ។

៤. <u>មាតាបិតា</u>ក្មេងទាំងពីរ ក៏អស់កង្វល់ក្នុងចិត្តដែរ ។



www.elibraryofcambodia.org

## ៦ រឿង ទឹកចិត្តមេមាន់



ចូរស្ដាប់រឿង និងបំពេញចន្លោះឱ្យត្រូវតាមខ្លឹមសាររឿងនៅពេលស្ដាប់ ។

### រឿង ទឹកចិត្តមេមាន់

កសិករម្នាក់បានចិញ្ចឹមមេមាន់មួយ និងមេទាមួយឱ្យនៅក្នុងទ្រុងជាមួយគ្នា ។ ក្រោយមកមេ ... កើតបានកូនបួន ចំណែកមេទាកើតបានកូនមួយក៏ ... ចោលកូនទៅ ។

មេមាន់ឃើញកូន ... កំព្រាក៏យកមកចិញ្ចឹមបីបាច់ដូចកូនបង្កើតដែរ ។ រាល់ថ្ងៃមេមាន់បណ្ដើរ ... ទាំងអស់រកចំណីគ្រប់ទីកន្លែង ។

ថ្ងៃមួយ កូន ... តូចជាងគេឆ្ងល់នឹងទង្វើរបស់ ... ក៏សួរ ៖ " ម៉ែ! ហេតុអ្វីបានជាម៉ែមើលថែកូនទា ?" ។ មេមាន់ឆ្លើយ ៖ " ... កំព្រាអត់មេ ហើយវានៅតូចណាស់ ។ វាត្រូវការ ការថែទាំដូចកូនដែរ ។ ម៉ែចិញ្ចឹមវា ព្រោះ ... ក៏មានសិទ្ធិរស់រានមានជីវិតដូចក្មេងទូទៅដែរ ។ បើម៉ែមិនយកវាមកចិញ្ចឹម តើវា .... ដូចម្ដេច ?" ។ កូនមាន់សួរមេវាទៀត ៖ " ម៉ែគិតចិញ្ចឹម ... រហូតឬ ? " ។ មេ ... ឆ្លើយ ៖ " ទេ ! ដល់វាគ្រប់អាយុម៉ែឱ្យវាទៅរៀនជាមួយកូន ហើយដល់ពេលវាអាចចិញ្ចឹមខ្លួនបាន ម៉ែឈប់ជួយវាហើយ " ។ " យី ! ម៉ែខ្ញុំចិត្តល្អណាស់ " កូន ... លាន់មាត់ ។



www.elibraryofcambodia.org

លំហាត់

ក. ចូរពន្យល់ពាក្យខាងក្រោមដោយប្រើវចនានុក្រម ឬបទានុក្រម ៖
ជីវភាព ប្រយោជន៍ កម្រៃ ឯកោ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ " ទុក ចិត្ត " ។

គ. ចូរសរសេរសេចក្តីសង្ខេបរឿងខាងលើ ។

ឃ. ចូរបង្ហាញផ្នែកនៃរឿងដែលមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ និងបង្ហាញមូលហេតុនៃការជ្រើសរើសនេះ ។

## ការរៀបព្រឹត្តិការណ៍រឿងតាមលំដាប់

ក. ចូរអានល្បះខាងក្រោម រួចដាក់លេខក្នុងប្រអប់ខាងមុខល្បះ ឱ្យបានត្រឹមត្រូវតាមលំដាប់ព្រឹត្តិការណ៍នៃរឿង "មេមាន់និងកូនទា" ។

- [១] មានមេមាន់មួយ ក្រាបពងទា ។
- [ ] ពេលមួយ វានាំកូនដល់មាត់ត្រពាំងទឹក ។
- [ ] កូនទា នាំគ្នាចុះហែលទឹកលេងកម្សាន្ត ។
- [ ] ដល់ពេលកូនញាស់ មេមាន់នាំកូនចុះមកដី ។
- [ ] មេមាន់បណ្តើរកូនរកចំណីក្នុងទីធ្លា ។
- [ ] វារត់ឆ្វេឆ្វា ហៅកូនទៅមាត់ត្រពាំង ។
- [ ] មេមាន់បារម្ភខ្លាំងណាស់ ខ្លាចកូនលង់ទឹក ។
- [ ] កូនទាលេងទឹកស្កប់ស្កល់ ដល់ពេលព្រលប់នាំគ្នាឡើងមកត្រសុលក្រោមស្លាបមេ ។
- [ ] ពេលណាកូនដើរបែកឆ្ងាយពីគ្នា មេមាន់ហៅកូនឱ្យមកជុំគ្នាវិញ ។
- [១០] មេមាន់ខឹងណាស់ ស្ទីបឆ្នោស ហើយបង្ខំកូនឱ្យចូលក្នុងសម្បុកវិញ ។

ខ. ចូរសរសេររឿងនេះ ឱ្យត្រូវតាមលំដាប់លំដោយនៃព្រឹត្តិការណ៍ ។



www.elibraryofcambodia.org

## រឿង អ្នកគ្រូរបស់គុណា



គុណាជាសិស្សសាលាបឋមសិក្សាភូមិបឹង ។ គេជាកូនកំព្រាឪពុកម្ដាយ ហើយរស់នៅជាមួយម្ដាយមីង ។ គុណាជាក្មេងឆ្លាត ស្លូតបូត ហើយឧស្សាហ៍ព្យាយាម ។ គុណាខិតខំរៀនសូត្រ ហើយធ្វើកិច្ចការដោយហ្មត់ចត់ ។ អ្នកគ្រូ និងសិស្សឯទៀតស្រឡាញ់គុណាគ្រប់ៗគ្នា ។ អ្នកគ្រូអាណិតគុណាណាស់ ព្រោះគុណាមានជីវភាពក្រីក្រជាងសិស្សឯទៀត ។

អ្នកគ្រូបានដឹងថា គុណាចូលចិត្ត និងប៉ិនប្រសប់ក្នុងការគូរគំនូរ ។ គាត់មានបំណងជួយគុណាឱ្យក្លាយជាជាងគំនូរដ៏ពូកែម្នាក់ ។ ថ្ងៃមួយអ្នកគ្រូ បានហៅគុណាមកសួរ ៖ " គុណាតើឯងចង់ក្លាយជាជាងគំនូរដែរ ឬទេ ?" ។ គុណាលើកដៃសំពះអ្នកគ្រូ ហើយឆ្លើយដោយស្រងូតស្រងាត់ ៖ " ជម្រាបប្រសាសន៍អ្នកគ្រូ ! ការងារនេះខ្ញុំចូលចិត្តណាស់ ប៉ុន្តែខ្ញុំមិនអាចធ្វើបានទេ " ។ អ្នកគ្រូញញឹមហើយនិយាយបន្ត ៖ " មិនអីទេ ! បើឯងពេញចិត្ត ខ្ញុំនឹងទៅនិយាយជាមួយឪពុកមាខ្ញុំឱ្យគាត់ជួយបង្រៀន ។ គាត់ជាជាងគំនូរដ៏ចំណានម្នាក់ ។ គាត់ចិត្តល្អណាស់ ។ គាត់ធ្លាប់ជួយក្មេងក្រីក្រដូចឯងពីរ បីនាក់រួចមកហើយ ។ ចំណែកខ្ញុំនឹងជួយផ្នែកសម្ភារៈ ។ ឯងកុំព្រួយអី គិតតែខំរៀនទៅ" ។ គុណាសំពះអរគុណអ្នកគ្រូ ។



www.elibraryofcambodia.org

ប៉ុន្មានថ្ងៃក្រោយមក ពេលទំនេរ គុណបានឆ្លៀតពេលទៅរៀនគូរគំនូរ ។ ពូធឿនបានជួយបង្រៀន គុណដោយស្មោះសរ ។ មិនយូរប៉ុន្មាន គុណអាចគូររូបភាពខ្លះៗ ។ គុណ បានជួយគូររូបភាពផ្សេងៗទុកជាសម្ភារៈ សម្រាប់អ្នកគ្រូយកមកបង្រៀនសិស្សរាល់ថ្ងៃ ។

ថ្ងៃមួយ ពូធឿនបានដឹងអំពីការប្រឡងគំនូរ សម្រាប់កុមារនៅក្នុងតំបន់ ។ គាត់បានប្រាប់គុណឱ្យគូរ ដើម្បីយកទៅចូលរួមប្រកួតប្រជែងនឹងគេ ។ ស្នាដៃរបស់គុណពេលនោះបានជាប់លេខ ២ ។ ក្រោយមកទៀត មានការប្រឡងម្តងទៀត ។ លើកទី ២ នេះ គុណទទួលបានលេខ ១ ព្រមទាំងទទួលបានរង្វាន់យ៉ាងច្រើន ។ គុណសប្បាយចិត្តណាស់ ។ គេរិតតែខំប្រឹងថែមមួយកម្រិតទៀត តែគេក៏មិនភ្លេចការរៀនសូត្រដែរ ។

ពីរឆ្នាំក្រោយមក ពូធឿនបានហៅគុណឱ្យទៅជួយគូរគំនូររបស់គាត់សម្រាប់លក់ ។ គាត់បានឱ្យកម្រៃខ្លះៗដល់គុណ គ្រាន់បានបន្តការរៀនសូត្រ ។ ក្រោយមកទៀត គុណបានចូលរៀនមហាវិទ្យាល័យវិចិត្រសិល្បៈ តាមការណែនាំរបស់អ្នកគ្រូ និងពូធឿន ។ គុណអាចរកប្រាក់បានបណ្តើរៗ ហើយក្រោយមក គេក៏ក្លាយជាជាងគំនូរដ៏ល្បីម្នាក់ ។ គុណមិនដែលភ្លេចគុណពូធឿន និងអ្នកគ្រូរបស់គេឡើយ ។

## សំណួរ

១. តើគុណជាក្មេងដូចម្តេច ?

២. តើអ្នកណាខ្លះបានជួយគុណ ? ជួយអ្វីខ្លះ ?

៣. ហេតុអ្វីបានជាគាត់ជួយគុណ ?

៤. នៅទីបញ្ចប់គុណក្លាយជាអ្វី ?

៥. តើអ្នកគ្រូក្នុងរឿងនេះ ជាមនុស្សដូចម្តេច ?



www.elibraryofcambodia.org

## គុណនាមសំណួរ

ចូរអានឧទាហរណ៍ខាងក្រោម ។ តើពាក្យណាខ្លះជាគុណនាមសំណួរ ?

១. តើកុមារមានសិទ្ធិមូលដ្ឋានប៉ុន្មានយ៉ាង ? គឺសិទ្ធិអ្វីខ្លះ ?

២. តើអ្នកចូលចិត្តរៀនមុខវិជ្ជាអ្វីជាងគេ ?

៣. តើតួអង្គព្រាហ្មណ៍ចិញ្ចឹមសត្វអ្វី ?

៤. តើកុមារណាខ្លះមិនទាន់បានចូលរៀន ?

៥. តើឯងទើបនឹងមកពីណា ?

ពាក្យ " ប៉ុន្មាន អ្វីខ្លះ អ្វី ស្អី ណាខ្លះ ណា " មានទីតាំងនៅខាងស្តាំនាម ហើយត្រូវបានប្រើប្រាស់សម្រាប់សួរអំពីមនុស្ស សត្វ វត្ថុ ។ វាជាគុណនាមសំណួរ ។

> គុណនាមសំណួរ ជាពាក្យសម្រាប់សួរ ។

គុណនាមសំណួរមាន : ប៉ុន្មាន អ្វី អ្វីខ្លះ ស្អី អី ណា ណាខ្លះ ... ។

### លំហាត់

ក. ចូរបំពេញល្បះដោយគុណនាមសំណួរសមស្រប ។

១. តើអ្នកមានឈ្មោះ ... ?

២. តើអ្នកមានបងប្អូន ... នាក់ ? ស្រី ... ?

៣. តើឪពុកអ្នកប្រកបមុខរបរ ... ?

៤. តើអ្នកធ្លាប់ទៅទស្សនាខេត្ត ... ?

៥. តើខេត្ត ... សម្បូរប្រាសាទបុរាណជាងគេ ?

ខ. ចូរបង្កើតល្បះដោយប្រើគុណនាមសំណួរខាងក្រោម ៖

អ្នកណា អ្វី ប៉ុន្មាន ណា អ្វីខ្លះ ណាខ្លះ ។



www.elibraryofcambodia.org

## ការនិយាយអំពីសិទ្ធិរបស់កុមារ

ពេលចេញពីសាលារៀន កនបានជួបនឹងកុមារម្នាក់នៅតាមផ្លូវ ។

ចូរស្តាប់ការសន្ទនារវាងកន និងកុមារនោះ ។

កន : កុល ! ឯងរែកអ្វីទៅណាហ្នឹង ?

កុល : អូបងកន ! ខ្ញុំរែកអុសទៅឱ្យគេនៅជិតផ្សារ ។

កន : តែឯងមិនគួររែកធ្ងន់យ៉ាងនេះទេណា !

កុល : បើខ្ញុំមិនធ្វើ តើបានអ្វីដោះស្រាយជីវភាព ? បងក៏ដឹងដែរថា ខ្ញុំជាក្មេងកំព្រា ។

កន : បងដឹង ! តែឯងក៏ពុំគួរប្រើកម្លាំងឱ្យហួសប្រមាណដែរ ។ ឯងត្រូវធ្វើពលកម្មតាមវ័យរបស់ខ្លួន និងគួរតែបានរៀនសូត្រដូចគេឯងដែរ ។

កុល : បើបានដូចបងនិយាយនោះ ខ្ញុំសប្បាយចិត្តណាស់ ។

កន : អូ ! បងនឹកឃើញហើយ ! បើឯងយល់ព្រម បងនឹងជម្រាបប៉ាបងឱ្យយកឯងទៅរស់នៅក្នុងមណ្ឌលកុមារកំព្រា ។ នៅទីនោះ គេនឹងចិញ្ចឹមឯងឱ្យឯងរៀនសូត្រ ហើយទទួលបានការការពារគ្រប់បែបយ៉ាង ។

កុល : ខ្ញុំសូមអរគុណបង ដែលជួយរកដំណោះស្រាយឱ្យខ្ញុំ ។

### លំហាត់

**ចូរអ្នកនិយាយអំពីការរៀនសូត្រ និងការការពារអ្វីខ្លះដែលអ្នកទទួលបានអំពីមាតាបិតា ឬអាណាព្យាបាលរបស់អ្នកប្រាប់មិត្តរួមថ្នាក់ ។**



www.elibraryofcambodia.org

# សំណេររបាយការណ៍ស្ដីពីអំណានរឿងសម្រាប់អ្នកស្ដាប់

ជាទូទៅ ការសរសេររបាយការណ៍ ស្ដីពីការអានរឿងសម្រាប់អ្នកស្ដាប់ត្រូវចែកជា ៣ផ្នែកធំ ដូចខាងក្រោម ៖

១. **សេចក្ដីផ្ដើម**

បញ្ជាក់ពេលវេលា ទីកន្លែង មូលហេតុនៃការអានរឿង ឈ្មោះរឿង និងអ្នកស្ដាប់ ។

២. **តួសេចក្ដី**

សរសេរសង្ខេបរឿងទាំងមូល ដោយប្រើពាក្យផ្ទាល់ខ្លួន ។

៣. **បញ្ចប់សេចក្ដី**

បង្ហាញចំណាប់អារម្មណ៍ចំពោះខ្លឹមសាររឿងដែលខ្លួនបានអាន ។

បញ្ជាក់ ៖ ដើម្បីឱ្យអ្នកស្ដាប់ចាប់អារម្មណ៍ អ្នកត្រូវចេះជ្រើសរើសរឿងណាដែលមានសារៈសំខាន់ចំពោះអ្នកស្ដាប់ រឿងដែលមានឧត្ដមគតិ និងផ្ដល់ជំបូន្មានដ៏ប្រពៃដល់អ្នកអានហើយត្រូវចេះនិយាយលើកដាក់សំឡេងតាមអារម្មណ៍របស់តួអង្គរឿងថែមទៀត ។

## លំហាត់គំរូ

អ្នកបានអានរឿង " អ្នកគ្រូរបស់គុណា " ឱ្យមិត្តរួមថ្នាក់ស្ដាប់ ។ ចូរប្អូនសរសេររបាយការណ៍មួយស្ដីពីអំណានរឿងនោះដោយ ៖

- ផ្ដល់សេចក្ដីសង្ខេបរឿង និងពន្យល់មូលហេតុនៃការជ្រើសរើស
- ដៅសម្គាល់ផ្នែកណា ដែលមានលក្ខណៈគួរឱ្យចាប់អារម្មណ៍នៅពេលអាន
- ពណ៌នាអំពីប្រតិកម្មរបស់អ្នកស្ដាប់
- វាយតម្លៃអំណានរបស់អ្នកលើចំណុចល្អ និងចំណុចដែលត្រូវកែលម្អ ។

ខាងក្រោមនេះ ជាគម្រោងលម្អិតស្ដីពីអំណានរឿង " អ្នកគ្រូរបស់គុណា " ។



www.elibraryofcambodia.org

# គម្រោងតែង

## ១. សេចក្តីផ្តើម

ពេលវេលា (ល្ងាចថ្ងៃសៅរ៍មួយ) ទីកន្លែង (នៅលើគ្រែក្រោមដើមស្វាយចំមួយដើម) មូលហេតុនៃការអានរឿង (ដើម្បីបង្កើតបរិយាកាសរីករាយ) អ្នកស្តាប់ (ប្អូនៗ) ។

## ២. តួសេចក្តី

- ការសង្ខេបរឿង (គុណាជាសិស្សសាលាបឋមសិក្សាភូមិបឹង) ។ គេជាកូនកំព្រា ... គុណាមិនដែលភ្លេចគុណពូធឿន និងអ្នកគ្រូរបស់គេឡើយ ។
- មូលហេតុនៃការជ្រើសរើស (ជារឿងទាក់ទងនឹងកុមារ ហើយកុមារគួរតែដឹងអំពីសិទ្ធិរបស់ពួកគេ) ។
- ផ្នែកដែលគួរចាប់អារម្មណ៍ (គុណាបានអ្នកគ្រូរបស់គេជួយជ្រោមជ្រែង រហូតបានក្លាយជាជាងគំនូរដ៏ល្បីម្នាក់) ។
- ការពណ៌នាអំពីប្រតិកម្មរបស់អ្នកស្តាប់ (ប្អូនៗពេញចិត្តនឹងអ្នកគ្រូដែលមានចិត្តល្អ អាណិតកុមារកំព្រាក្រីក្រ) ។
- ការវាយតម្លៃអំណាន (ចំណុចល្អ : អានគ្មានរដាក់រដុបតាំងពីការផ្តើមរឿង រហូតដល់បញ្ចប់រឿង ។ ចំណុចត្រូវកែលម្អ : មិនទាន់ចេះប្រើការលើកដាក់សំឡេងឱ្យត្រូវតាមមនោសញ្ចេតនារបស់តួអង្គ) ។

## ៣. បញ្ចប់សេចក្តី

រឿង " អ្នកគ្រូរបស់គុណា" ជារឿងមួយដែលបង្ហាញអំពីទឹកចិត្តគ្រូចំពោះសិស្ស ជាពិសេសសិស្សក្រីក្រ ឬកុមារកំព្រា ។ ខន្តីមនឹងការខិតខំប្រឹងប្រែងបង្រៀនសិស្សឱ្យចេះនិងក្លាយជាមនុស្សល្អ គ្រូបានជួយជ្រោមជ្រែង និងលះបង់ថវិកាខ្លះ ដើម្បីឱ្យសិស្សដែលជួបការលំបាក ដើម្បីគេមានអនាគតរុងរឿងទៀតផង ។



www.elibraryofcambodia.org

លំហាត់

ក. ចូរអ្នកមើលរូបភាព រួចសរសេររឿងតាមលំដាប់លំដោយ ។
ចូរនិទានរឿងនេះឱ្យមិត្តរួមថ្នាក់ស្ដាប់ ។




ខ. អ្នកបានអានរឿង "ព្រាហ្មណ៍និងស្ការ" ឱ្យសិស្សតូចៗស្ដាប់ ។ ចូរអ្នកសរសេររបាយការណ៍ ស្ដីពីការអានរឿងនេះឱ្យសិស្សតូចៗស្ដាប់ដោយ ៖

- ផ្ដល់សេចក្ដីសង្ខេបរឿង និងពន្យល់មូលហេតុនៃការជ្រើសរើសរឿងនេះ
- ប្រាប់ផ្នែកណាដែលលំបាក ឬមានលក្ខណៈគួរឱ្យចាប់អារម្មណ៍នៅពេលអាន
- ពណ៌នាអំពីប្រតិកម្មរបស់អ្នកស្ដាប់
- វាយតម្លៃការអានរបស់អ្នកលើចំណុចល្អ និងចំណុចដែលត្រូវកែលម្អ ។

បញ្ជាក់ ៖ អ្នកអាចជ្រើសរើសរឿងផ្សេងទៀត ដែលផ្ដល់ការអប់រំល្អ ។



www.elibraryofcambodia.org

មេរៀនទី ៨

# ធនធានរ៉ែនៅប្រទេសកម្ពុជា



ប្រទេសកម្ពុជាមានសម្បត្តិធម្មជាតិនៅក្នុងទឹក លើដី និងក្នុងដី ។ រ៉ែជាសម្បត្តិធម្មជាតិមួយប្រភេទដែលរួមចំណែកជំរុញសេដ្ឋកិច្ចជាតិ ឱ្យរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័ស ។ រ៉ែទាំងនោះ មានដូចជា រ៉ែដែក រ៉ែមាស រ៉ែត្បូង រ៉ែប្រេងកាត ... ។



www.elibraryofcambodia.org

## ការកត់ត្រាចំណុចសំខាន់ៗនៃព័ត៌មាន

ពេលអ្នកស្ដាប់ ឬអានអត្ថបទព័ត៌មាន អ្នកគួរកត់ត្រាចំណុចសំខាន់ៗទុក ព្រោះវាជួយអ្នកឱ្យចងចាំព្រឹត្តិការណ៍ ឬហេតុការណ៍សំខាន់ៗដែលអ្នកបានស្ដាប់ ឬអាន និងងាយស្រួលក្នុងការសង្ខេបអត្ថបទនោះ ។ ការកត់ត្រានេះ មិនទាមទារឱ្យអ្នកសរសេរជាល្បះពេញលេញទេ ។ អ្នកគ្រាន់តែសរសេរពាក្យ ឬកន្សោមពាក្យសំខាន់ៗរបស់ព័ត៌មានប៉ុណ្ណោះ ។

ចូរអ្នកអានអត្ថបទខាងក្រោម ។ ពាក្យ ឬកន្សោមពាក្យដែលមានគំនូសពីក្រោម ជាពាក្យសំខាន់ដែលត្រូវកត់ត្រាទុក ។

### ថ្មកំបោរ

ភ្នំថ្មកំបោរនៅខេត្តកំពត ជាភ្នំដែលមានថ្មខុសប្លែកពីថ្មភ្នំដទៃទៀតនៅកម្ពុជា ។ កាលដើមឡើយ ប្រជាជនខ្មែរយើងពុំទាន់យល់ច្បាស់អំពីអត្ថប្រយោជន៍នៃថ្មកំបោរនៅឡើយទេ ។ គេនាំគ្នាទៅយកថ្មកំបោរពីភ្នំមកបញ្ចូលក្នុងឡដុតធ្វើកំបោរ សម្រាប់លក់ចែកចាយដល់អ្នកហូបម្លូ និងធ្វើជាកំបោរម៉ដ្ឋសម្រាប់លាបផ្ទះ លាបចិញ្ចើមថ្នល់ គល់ឈើលម្អក្នុងពិធីបុណ្យជាតិផ្សេងៗ ។ ជួនកាល គេយកថ្មកំបោរទៅរោយក្នុងរោង ឬទ្រុងចិញ្ចឹមសត្វ កន្លែងកខ្វក់ដើម្បីសម្លាប់មេរោគ ។

នៅឆ្នាំ ១៩៦៤-១៩៦៥ ក្រោមជំនួយឧបត្ថម្ភពីប្រទេសចិន ប្រទេសកម្ពុជាបានសាងសង់រោងចក្រស៊ីម៉ងត៍ នៅចក្រីទីងក្នុងខេត្តកំពត ។

ក្រោយពីរោងចក្រនេះដំណើរការ តម្លៃស៊ីម៉ងត៍នៅក្នុងប្រទេសថោកជាងស៊ីម៉ងត៍នាំចូលពីបរទេស រីឯគុណភាពក៏មិនចាញ់ស៊ីម៉ងត៍នាំចូលពី ប្រទេសក្រៅ ឡើយ ។ សំណង់គ្រប់យ៉ាង ប្រើប្រាស់តែស៊ីម៉ងត៍នៅចក្រីទីងប៉ុណ្ណោះ ។

ចំណុចសំខាន់ៗនៃអត្ថបទខាងលើមាន ៖

កន្លែងមានថ្មកំបោរ ៖ ភ្នំថ្មកំបោរ ខេត្តកំពត

ផលបានពីថ្មកំបោរ ៖ កំបោរសម្រាប់អ្នកហូបម្លូស្លា កំបោរម៉ដ្ឋ ស៊ីម៉ងត៍

ការប្រើប្រាស់ ៖ ធ្វើសំណង់ ហូបជាមួយម្លូ លាបផ្ទះ ចិញ្ចើមថ្នល់ ដើមឈើ រោយក្នុងទ្រុងសត្វ កន្លែងកខ្វក់ ដើម្បីសម្លាប់មេរោគ



www.elibraryofcambodia.org

ការផលិត ៖ ឆ្នាំ១៩៦៤-១៩៦៥ ក្រោមជំនួយឧបត្ថម្ភរបស់ប្រទេសចិន ប្រទេសកម្ពុជាបានសង់រោងចក្រស៊ីម៉ង់ត៍នៅចក្រីទីង

គុណភាពស៊ីម៉ង់ត៍ ៖ មិនចាញ់ស៊ីម៉ងត៍បរទេស តម្លៃថោក ។

ដើម្បីកត់ត្រាចំណុចសំខាន់ៗ អ្នកត្រូវយកចិត្តទុកដាក់លើព័ត៌មាន មួយចំនួនខាងក្រោម ៖

- សេចក្ដីលម្អិតសំខាន់ៗ ដូចជាហេតុការណ៍ ឬព្រឹត្តិការណ៍គួរចាប់អារម្មណ៍ ឬឧទាហរណ៍ដែលគេលើកមកបញ្ជាក់ ជួនកាលមានមតិ ឬយោបល់ផ្សេងៗ ។
- កាលបរិច្ឆេទសំខាន់ៗ (ប្រសិនបើមាន) ។
- មនុស្សសំខាន់ៗ (ប្រសិនបើមាន) ។

ការកត់ត្រាចំណុចសំខាន់ៗ គឺការកត់ត្រាពាក្យ ឬកន្សោមពាក្យខ្លីៗ ដែលប្រាប់គំនិតសំខាន់ៗរបស់ព័ត៌មានក្នុងអត្ថបទ ។

លំហាត់

**ចូរអានអត្ថបទព័ត៌មានខាងក្រោម រួចកត់ត្រាចំណុចសំខាន់ៗ ។**

នៅប្រទេសកម្ពុជាមានរ៉ែច្រើនប្រភេទ ។ រ៉ែទាំងអស់ ស្ថិតនៅក្នុងជម្រៅមិនស្មើគ្នាទេ ។ រ៉ែខ្លះអាចនៅស្រទាប់ខាងលើ រ៉ែខ្លះទៀតស្ថិតនៅយ៉ាងជ្រៅ ក្រោមបាតសមុទ្រ ដូចជារ៉ែប្រេងកាតជាដើម ។ ពេលគេយករ៉ែប្រេងកាតបានមក គេមិនអាចប្រើប្រាស់ភ្លាមបានទេ ។ គេត្រូវចម្រាញ់ប្រេងនោះឱ្យបានជាប្រេងឥន្ធនៈផ្សេងៗ សម្រាប់ឱ្យម៉ាស៊ីននានាមានដំណើរការ ។ គេយករ៉ែដែកទៅស្ល ដើម្បីឱ្យបានជាដែកសុទ្ធ ។ គេយករ៉ែមាសនិងត្បូងតាមរយៈការជីកដីយកទៅលាងក្នុងទឹក ។ គេយកកម្ទេចមាសទៅធ្វើអគ្គិសនីវិភាគយកមាសសុទ្ធ ។ ចំណែកត្បូង គេយកទៅច្នៃធ្វើគ្រឿងអលង្ការទុកលក់ដូរ និងប្រើប្រាស់តាមសេចក្ដីត្រូវការ ។



www.elibraryofcambodia.org

## ធនធានធម្មជាតិនៅក្នុងដី

| ឈ្មោះរ៉ែ | ទីកន្លែងមានរ៉ែ | |
|---|---|---|
| | ឈ្មោះភូមិ ស្រុក | ឈ្មោះខេត្ត |
| ១. រ៉ែដែក | ស្រុករវៀង | ព្រះវិហារ |
| | ភ្នំដី ស្រុកសណ្ដាន់ | កំពង់ធំ |
| ២. រ៉ែមាស | ស្រុករវៀង ស្រុកអណ្ដូងមាស | ព្រះវិហារ-រតនគិរី |
| | ស្រុកតាវែង ស្រុកថ្មបាំង | កោះកុង |
| ៣. រ៉ែត្បូង | កាទី មេម៉ង់ ស្រុកកែវសីមា | មណ្ឌលគិរី |
| | ភ្នំយ៉ាត បយ៉ាខា បតាំងស៊ូ | ខេត្តប៉ៃលិន |
| | ស្រុកបកែវ ស្រុកកូនមុំ ស្រុកលំផាត់ | រតនគិរី |
| ៤. រ៉ែប្រេងកាត | សមុទ្រខ្មែរ បឹងទន្លេសាប | កោះកុង ខេត្តព្រះសីហនុ បឹងទន្លេសាប |

ប្រទេសកម្ពុជាមានក្រឡាផ្ទៃ តូចជាងប្រទេសជិតខាង ប៉ុន្តែសម្បូរទៅដោយភោគទ្រព្យរ៉ែផ្សេងៗ ។ ភោគទ្រព្យទាំងនេះ ធ្វើឱ្យប្រជាជនមានមោទនភាព និងមានទឹកចិត្តស្រឡាញ់ប្រទេសជាតិខ្លួន ជាពិសេសប្រជាជនដែលរស់នៅតំបន់មានរ៉ែ ។

រ៉ែដែកសម្បូរនៅស្រុករវៀង ខេត្តព្រះវិហារ និងភ្នំដីស្រុកសណ្ដាន់ ខេត្តកំពង់ធំ ។ សព្វថ្ងៃ ក្រុមហ៊ុនចិន បានសង់រោងចក្រស្លដែកមួយនៅចំណុចប្រសព្វនៃខេត្តស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ ។ រ៉ែមាស ភាគច្រើនមាននៅស្រុករវៀង ខេត្តព្រះវិហារ ស្រុកអណ្ដូងមាស ស្រុកតាវែង ខេត្តរតនគិរី និងស្រុកថ្មបាំងខេត្តកោះកុង ។ អ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីបានផ្ដល់ព័ត៌មានថា ក្នុងភូមិសាស្ត្រកាទីនិងមេម៉ង់ស្រុកកែវសីមា ខេត្តមណ្ឌលគីរីមានមាសប្រហែលជាងប្រាំបីលានតោន ។



www.elibraryofcambodia.org

នៅភ្នំយ៉ាត បយ៉ាខា បតាំងស៊ូ ក្នុងខេត្តប៉ៃលិនពីមុនមានរ៉ែត្បូងល្អប្រណីត និងមានតម្លៃជាងគេដូចជាត្បូងទទឹម និងត្បូងកណ្ដៀង ។ នៅស្រុកបរកែវ កូនមុំ និងលំផាត់ខេត្តរតនគិរី ក៏សម្បូរត្បូងធម្មជាតិដែរ ។ ពេលថ្មីៗនេះ នៅស្រុកគិរីវង់ ខេត្តតាកែវគេបានរកឃើញរ៉ែត្បូងមួយចំនួន តែគុណភាពអន់ជាងត្បូងនៅរតនគិរី និងប៉ៃលិន ។ ក្រៅពីធ្វើគ្រឿងអលង្ការសម្រាប់ពាក់លម្អ គេបាននាំយកត្បូងទាំងនេះ ទៅលក់ឯបរទេសទៀតផង ។

នៅបាតសមុទ្រខ្មែរ និងនៅបឹងទន្លេសាប គេបានរកឃើញរ៉ែពិសេសមួយទៀត គឺរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិ ។ បច្ចុប្បន្ន ក្រុមហ៊ុនបរទេសមួយចំនួនកំពុងធ្វើវិនិយោគ ដើម្បីបូមប្រេងកាត និងឧស្ម័នពីបាតសមុទ្រខ្មែរ ។

យើងជាខ្មែរត្រូវមានការប្រុងប្រយ័ត្នជានិច្ច ក្នុងការទាញយកភោគទ្រព្យធម្មជាតិដ៏មានតម្លៃទាំងនេះ ដោយមិនជីកយករ៉ែដែលនៅខ្ចី ឬខុសបច្ចេកទេសដែលធ្វើឱ្យហិនហោច ខាតបង់ដល់ប្រទេសជាតិនៅថ្ងៃអនាគតនោះទេ ។

សំណួរ

១. តើរ៉ែច្រើនមាននៅក្នុងខេត្តណាខ្លះ ?

២. តើខេត្តណាខ្លះមានរ៉ែដែក ? ខេត្តណាខ្លះមានរ៉ែមាស ? ខេត្តណាខ្លះមានរ៉ែត្បូង ? តើរ៉ែប្រេងកាតមាននៅតំបន់ណាខ្លះ ?

៣. តើរ៉ែទាំងនោះ មានប្រយោជន៍អ្វីខ្លះ ?

៤. ហេតុអ្វីបានជាយើងត្រូវប្រុងប្រយ័ត្ន ក្នុងការទាញយកធនធានរ៉ែទាំងនោះ ?

៥. តើគេសរសេរព័ត៌មានខាងលើ ក្នុងគោលបំណងអ្វី ?

៦. តើគេសរសេរព័ត៌មានទាំងនេះ សម្រាប់អ្នកណាខ្លះ ?

លំហាត់

ក. ចូរហាត់អាន និងពន្យល់ន័យពាក្យពហុព្យាង្គខាងក្រោម ៖

ព័ត៌មាន ភូមិសាស្ត្រ បច្ចុប្បន្ន វិនិយោគ អលង្ការ រដ្ឋាភិបាល ។



www.elibraryofcambodia.org

ខ. ចូររកពាក្យដែលមានន័យដូចគ្នាមកជំនួសពាក្យដែលមានគំនូសពីក្រោម ។

១. ប្រជាជនមានទឹកចិត្ត ស្រឡាញ់ ប្រទេសជាតិខ្លួន ។

២. មិនបានសង់រោងចក្រស្លដែកនៅ ចំណុចប្រសព្វ នៃខេត្តស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ ។

៣. អ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីបានផ្ដល់ ព័ត៌មាន ថា ... ។

៤. បច្ចុប្បន្ន ក្រុមហ៊ុនចិនបានធ្វើវិនិយោគទុនរើមាសនៅទីនោះ ។

៥. គេបាននាំយកត្បូងទាំងនេះទៅលក់ឱ្យ បរទេស ។

គ. ចូរកត់ត្រាចំណុចសំខាន់ៗនៃព័ត៌មាន នៅក្នុងអត្ថបទខាងលើ ។

## ៦ ត្បូងពណ៌ស្វាយមួយគ្រាប់



ចូរបំពេញចន្លោះក្នុងអត្ថបទខាងក្រោម ឱ្យត្រូវតាមព័ត៌មានដែលអ្នកកំពុងស្ដាប់ ។

ខេត្តរតនគិរីសម្បូរទៅដោយ ... ធម្មជាតិដ៏មានតម្លៃគួរកត់សម្គាល់ ដូចជានៅស្រុក... ស្រុកលំផាត់ និងស្រុក ... ។

កាលពីខែតុលាឆ្នាំ... នៅអូរខ្នេះ ភូមិ ... ឃុំត្រពាំងក្រហម ស្រុកកូនមុំគេជីកបានត្បូងធម្មជាតិពណ៌... មួយគ្រាប់ ទម្ងន់ ... គីឡូក្រាម ។ គេបានលក់... នេះ ទៅឱ្យកុងសៃទិញត្បូងម្នាក់នៅក្នុងខេត្តរតនគិរី តែពុំដឹងលក់ក្នុងតម្លៃប៉ុន្មានទេ ។

ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តរតនគិរីបានឱ្យដឹងថា ត្បូងពណ៌ស្វាយមួយគ្រាប់នេះ មិនមែនប្រភេទ ... នោះទេ គឺជាកែវណាមហ្សានពណ៌ ... ។ កែវណោមហ្សាននេះជា ... ប្រភេទទី ។ ថ្មកែវណាមហ្សាន មានពណ៌ស្វាយល្អណាស់ ពេលគេជីកបានពីក្នុង... តែក្រោយមក វាប្រែពណ៌ ... មិនសូវល្អ ដូចពេលគេជីកបានភ្លាមទេ ។



www.elibraryofcambodia.org

## សំណួរ

១. តើខេត្តរតនគិរីសម្បូរអ្វី ?

២. តើគេជីកត្បូងពណ៌ស្វាយនៅឯណា ?

៣. តើកែវណាមហ្សានជាអ្វី ?

៤. តើថ្មកែវណាមហ្សានមានពណ៌ដូចម្ដេចនៅពេលគេទើបនឹងជីកបាន ?

## លំហាត់

ក. ចូរគត់ត្រាចំណុចសំខាន់ៗនៃអត្ថបទខាងលើ ។

ខ. ចូរបង្ហាញប្រធានបទនៃអត្ថបទខាងលើ ដោយជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

១. ការលក់ត្បូងនៅខេត្តរតនគិរី

២. ត្បូងពណ៌ស្វាយមួយគ្រាប់នៅខេត្តរតនគិរី

៣. របរជីកត្បូងនៅខេត្តរតនគិរី

## ៣-១ គុណនាមចង្អុល

គុណនាមកំណត់មានច្រើនប្រភេទ ដូចជាគុណនាមចង្អុល គុណនាមសំណួរ គុណនាមកម្មសិទ្ធិ គុណនាមចំនួន និងគុណនាមមិនច្បាស់ ។ មេរៀននេះ អ្នករៀនអំពីគុណនាមចង្អុល ។

**ចូរពិនិត្យឧទាហរណ៍ខាងក្រោម តើពាក្យណាខ្លះជាគុណនាមចង្អុល ។**

១. ភ្នំនោះមានឈ្មោះថា ភ្នំថ្មកំបោរ ។

២. គេរកឃើញវិហារទាំងនេះនៅខេត្តមណ្ឌលគិរី ។

៣. នៅបរកែវមានត្បូងល្អៗជាច្រើន ។ ឈ្មួញបរទេសនិយមទិញត្បូងទាំងនោះណាស់ ។

៤. មនុស្សនេះជាអ្នកស្រាវជ្រាវរករ៉ែនៅកម្ពុជា ។



www.elibraryofcambodia.org

ពាក្យ "នោះ ទាំងនេះ ទាំងនោះ នេះ" ជាគុណនាមចង្អុល ។

> គុណនាមចង្អុល ជាពាក្យសម្រាប់បង្ហាញមនុស្ស សត្វ វត្ថុ រុក្ខជាតិ នៅជិតមុខ ឬនៅឆ្ងាយ ឬបង្ហាញអ្វីដែលគេទើបនឹងប្រាប់ ឬដែលគេបម្រុងនឹងប្រាប់ ។

គុណនាមចង្អុលមាន ៖ នេះ នោះ ទាំងនេះ ទាំងនោះ នុះ ។

- នេះ បង្ហាញ មនុស្ស សត្វ វត្ថុ ដែលនៅជិតខ្លួន ឬបង្ហាញអ្វីដែលគេបម្រុងនឹងនិយាយប្រាប់ ។
- នោះ បង្ហាញអ្វីដែលនៅឆ្ងាយ ឬអ្វីដែលគេទើបនឹងប្រាប់ ។
- នុះ បង្ហាញអ្វីដែលនៅឆ្ងាយតែមើលឃើញ ។

បញ្ជាក់ : គុណនាមចង្អុល នេះ នោះ ទាំងនេះ ទាំងនោះ នុះ តែងតែនៅជាប់ខាងស្តាំនាម ។

## លំហាត់

ក. ចូរស្រង់គុណនាមចង្អុលនៅក្នុងល្បះខាងក្រោម ៖

១. គេទើបនឹងរកឃើញរ៉ែត្បូងទាំងនេះនៅស្រុកគិរីវង់ ខេត្តតាកែវ ។
២. បុរសពាក់អាវសនេះ ជាកុងសៃទិញត្បូងនៅខេត្តរតនគិរី ។
៣. គេចិញ្ចឹមគោទាំងនោះ ទុកលក់យកសាច់ ។
៤. ដើមឈើនោះ ច្រើនដុះនៅជិតភ្នំ ។
៥. ភ្នំនោះជាភ្នំថ្មកំបោរ ។

ខ. ចូរបង្កើតល្បះដោយប្រើគុណនាមចង្អុល "នេះ នោះ ទាំងនេះ ទាំងនោះ" ឱ្យបានមួយល្បះក្នុងមួយពាក្យ ។

គ. ចូរប្រាប់លេខល្បះដែលមានគុណនាមចង្អុល ព្រមទាំងស្រង់ពាក្យទាំងនោះផង ។

១. នោះជាភ្នំដែក នៅខេត្តកំពង់ធំ ។
២. គេទើបនឹងរកឃើញវត្ថុនេះ នៅក្នុងខេត្តយើង ។
៣. នេះជាមធ្យោបាយល្អបំផុត ។
៤. យើងត្រូវថែរក្សារ៉ែទាំងនោះ ឱ្យនៅគង់វង្ស ។

# រ៉ែប្រេងកាត




ប្រេងកាតជារ៉ែមួយប្រភេទដែលមានតម្លៃជាងគេនៅលើពិភពលោក ។ នៅប្រទេសកម្ពុជា គេរកឃើញរ៉ែប្រេងកាតនៅក្នុងដី ក្រោមបាតសមុទ្រ និងក្រោមដីបាតបឹងទន្លេសាប ។ បច្ចុប្បន្ននេះ ក្រុមហ៊ុនវិនិយោគទុនជាច្រើនកំពុងចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីបូមប្រេងកាតនៅក្នុងសមុទ្រខ្មែរ ។

តាមអ្នកស្រាវជ្រាវបានឱ្យដឹងថា ប្រេងកាតនៅប្រទេសកម្ពុជាមានរាប់ពាន់បារ៉ែល ។ គេធ្វើសំណង់បូមប្រេងក្នុងទឹកសមុទ្រ ឬទឹកសាប ។ គេបុកទម្លុះដីមិនជ្រាបទឹក ដោយឆ្លងកាត់ស្រទាប់ដែលមានឧស្ម័ន ។ នៅស្រទាប់ខាងក្រោមប្រេង មានទឹកប្រៃ ។ នៅក្រោមទឹកប្រៃ មានស្រទាប់ដីដែលជាទម្រទឹកប្រៃ ។ នៅក្នុងស្រទាប់ឧស្ម័ន ក្នុងស្រទាប់ប្រេងកាត និងក្នុងស្រទាប់ទឹកប្រៃ គេសង្កេតឃើញមានសិលាស្លាត ។ នៅពេលបុកបំពង់ដល់ឧស្ម័ន គេដឹងថាជិតដល់ស្រទាប់ប្រេងហើយ ដូច្នេះគេមានការប្រុងប្រយ័ត្ន



www.elibraryofcambodia.org

មិនឱ្យការបុកនេះ ជ្រុលហួសនាំឱ្យប្រេងកាតបាញ់ឡើងខ្លាំងហួសបំពង់បង្ហូរ ។ ប្រេងដែលគេបូមពីក្នុងដី ត្រូវហូរចូលបំពង់បង្ហូរទៅកាន់រោងចក្រចម្រាញ់ប្រេងកាត ។ គេបានប្រេងច្រើនប្រភេទពីការចម្រាញ់ប្រេងឆៅដូចជា ប្រេងកាតសម្រាប់យន្តហោះ ប្រេងសាំង ប្រេងកាត ប្រេងម៉ាស៊ូត ប្រេងរំអិល និងកាកសំណល់សម្រាប់ចាក់ក្រាលផ្លូវថ្នល់ ។

ប្រេងកាតឆៅ ឬ "មាសខ្មៅ" មានប្រយោជន៍ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រទេស ។ ដូច្នេះ កូនខ្មែរគ្រប់រូបត្រូវចូលរួមថែរក្សាសម្បត្តិធម្មជាតិ ទាំងក្នុងដី ទាំងក្នុងទឹក ឱ្យបានគង់វង្សជារៀងរហូត ។

សំណួរ

១. តើប្រេងកាតមាននៅទីណាខ្លះ ?

២. តើគេត្រូវធ្វើដូចម្ដេច ដើម្បីយកប្រេងកាតឆៅបាន ?

៣. តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលដែលប្រទេសអ្នកមានអណ្ដូងប្រេងកាតបែបនេះ ?

៤. តើគេទទួលបានអ្វីខ្លះពីការចម្រាញ់ប្រេងឆៅ ?

លំហាត់

ក. ចូររកពាក្យផ្ទុយនឹងពាក្យ ៖

ទឹកសាប ក្រោមទឹក មានប្រយោជន៍ រីកចម្រើន ឆាប់រហ័ស ។

ខ. ចូរបង្ហាញគោលបំណងរបស់អត្ថបទខាងលើ ។

គ. ចូរកត់ត្រាចំណុចសំខាន់ៗរបស់អត្ថបទខាងលើ ។



www.elibraryofcambodia.org

# ការរៀបរាប់អំពីរ៉ែផ្សេងៗ

លោកគ្រូរបស់វិច្ឆិកាបានទទួលព័ត៌មានតាមវិទ្យុជាតិអំពីការវិនិយោគលើរ៉ែដែក នៅកម្ពុជា ។ គាត់បានយកព័ត៌មានទៅផ្សព្វផ្សាយបន្ត ដល់សិស្សរបស់គាត់ ។

ចូរស្ដាប់ការសន្ទនារបស់លោកគ្រូនិងសិស្សរបស់គាត់ ។

លោកគ្រូ : កាលពីព្រឹកមិញ លោកគ្រូបានទទួលព័ត៌មានថា មានក្រុមហ៊ុនមួយ កំពុងដាក់វិនិយោគខុសនៅតំបន់មានរ៉ែដែក ។ តើកូនៗបានដឹងឬទេ?

វិច្ឆិកា : ខ្ញុំមិនបានដឹងទេលោកគ្រូ ។ តើប្រទេសយើងមានរ៉ែដែកនៅឯណាខ្លះ ?

លោកគ្រូ : រ៉ែដែកក្នុងប្រទេសយើងមាននៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និង ខេត្តកំពង់ធំ ។

កុម្ភៈ : លោកគ្រូ! តើគេធ្វើដូចម្ដេច ដើម្បីយករ៉ែដែកមកប្រើប្រាស់បាន ?

លោកគ្រូ : ក្រុមហ៊ុនបានសាងសង់រោងចក្រស្លដែកមួយ នៅត្រង់ចំណុចប្រសព្វ ខេត្តទាំងបីខាងលើ ។ គេយករ៉ែដែកជីកបាន ទៅបញ្ចូលរោងចក្រទើប អាចបានដែកប្រើប្រាស់ ។

វិច្ឆិកា : លោកគ្រូ! តើដែកដែលគេស្លរួច ជាដែកប្រភេទណា ?

លោកគ្រូ : ដែកចេញពីរោងចក្រមានពីរប្រភេទ គឺដែករឹងល្អគេហៅថា ដែកថែប និងដែកធម្មតាដែលកូនឃើញគេលក់រាល់ថ្ងៃ ។

កុម្ភៈ : គិតទៅរ៉ែដែក ក៏មានប្រយោជន៍មិនចាញ់រ៉ែផ្សេងៗដែរមែនទេលោកគ្រូ?

លោកគ្រូ : មែនហើយ! រ៉ែទាំងអស់សុទ្ធតែជាធនធានដ៏មានតម្លៃបំផុត សម្រាប់ ប្រទេសនីមួយ ៗ ។

លំហាត់

ចូរអ្នកចាប់គូ ហើយនិយាយប្រាប់គ្នាអំពីរ៉ែណាមួយដែលអ្នកបានដឹងដោយប្រាប់ ឈ្មោះរ៉ែ ទីកន្លែងមានរ៉ែនោះ និងផលប្រយោជន៍របស់វា ។



www.elibraryofcambodia.org



ខេត្តនីមួយៗនៅប្រទេសកម្ពុជា មានធនធានធម្មជាតិដោយឡែកៗពីគ្នា ។ ថ្មីៗនេះ នៅខេត្តមណ្ឌលគិរី គេប្រទះឃើញធនធានក្នុងដីដ៏មានតម្លៃមួយទៀត គឺរ៉ែមាស ។

អ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីបានផ្តល់ព័ត៌មានថា គេបានរកឃើញរ៉ែមាសប្រហែលជាងប្រាំបីលានតោននៅកាទី និងមេម៉ង់ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ។ ផ្នែកខ្លះនៃរ៉ែមាសក្នុងស្រុកនេះ បានត្រូវក្រុមហ៊ុនចិនធ្វើវិនិយោគរួចទៅហើយ ។ រ៉ែមាសនៅមណ្ឌលគិរី ជារ៉ែមាសដែលមានគុណភាពល្អ អាចយកទៅធ្វើជាគ្រឿងអលង្ការផ្សេងៗ សម្រាប់ប្រើប្រាស់ ឬសម្រាប់លក់ដូរបាន ។

រ៉ែមាសមិនមែនមានតែនៅខេត្តមណ្ឌលគិរីទេ នៅស្រុករវៀង ខេត្តព្រះវិហារក៏មានរ៉ែមាសដែរ ។ ប្រជាជននៅទីនោះ យកការរែងរ៉ែមាសជារបរចិញ្ចឹមជីវិតតាំងពីយូរណាស់មកហើយ ។ ពួកគេរែងមាស ដោយកម្លាំងពលកម្មសុទ្ធសាធ ។ គេអាចរកមាសសុទ្ធបានពីប្រាំជីទៅមួយតម្លឹងក្នុងមួយសប្តាហ៍ ឬយ៉ាងហោចណាស់ក៏បាន ២ឬ៣ជីមាសធម្មតាដែរ ។



www.elibraryofcambodia.org

គេអាចយករ៉ែមាសបានដោយការជីកលុងដី រហូតដល់គេប្រទះឃើញស្រទាប់ដីពណ៌លឿងជាខ្សែៗ ។ គេយកដីនោះទៅរែង រួចគេយកទៅធ្វើអគ្គិសនីវិភាគយកមាសសុទ្ធ ។ គេត្រូវប្រែក្លាយវាឱ្យទៅជាមាសទឹកដប់សុទ្ធ ។

មាសជារូបិយប័ណ្ណសំខាន់ សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ ។ ក្នុងនាមជាកុលបុត្រកុលធីតាខ្មែរ ត្រូវជួយថែរក្សាសម្បត្តិធម្មជាតិទាំងនេះឱ្យគង់វង្សបានយូរអង្វែង ដើម្បីឱ្យប្រទេសជាតិបានរីកចម្រើន ដូចប្រទេសនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសជឿនលឿនលើពិភពលោក ។

## សំណួរ

១. តើរ៉ែមាសមាននៅខេត្តណាច្រើនជាងគេ ?

២. តើគេធ្វើដូចម្ដេច ដើម្បីយកមាសបាន ?

៣. តើគេធ្វើដូចម្ដេច ដើម្បីឱ្យរ៉ែមាសទៅជាមាសសុទ្ធ ?

៤. តើរ៉ែមាសផ្ដល់ប្រយោជន៍អ្វីខ្លះ ដល់ប្រជាជននិងប្រទេសជាតិ ?

៥. តើការជីកយកមាសដោយកម្លាំងពលកម្មសុទ្ធសាធ អាចធ្វើឱ្យសម្បត្តិធម្មជាតិហិនហោចខាតបង់រហ័សដែរ ឬទេ ?

## លំហាត់

ក. ចូរអាននិងពន្យល់ន័យពាក្យពហុព្យាង្គខាងក្រោម ៖

អគ្គិសនី រូបិយប័ណ្ណ សេដ្ឋកិច្ច កុលបុត្រ កុលធីតា អាស៊ីអាគ្នេយ៍ ។

ខ. ចូររកពាក្យដែលមានន័យដូចនឹងពាក្យ ៖

មាសសុទ្ធ គង់វង្ស រីកចម្រើន ជឿនលឿន ។

គ. ចូរស្រង់គុណនាមចង្អុលនៅក្នុងអត្ថបទខាងលើ ។



www.elibraryofcambodia.org

# អត្ថបទព័ត៌មានខ្លី

ចូរអ្នកពិនិត្យតារាងបង្ហាញព័ត៌មានអំពី "ធនធានធម្មជាតិក្រោមដី" រួចអានអត្ថបទអំណានដែលនៅពីខាងក្រោម ដោយយកចិត្តទុកដាក់ ដើម្បីជាទុនក្នុងការធ្វើលំហាត់ខាងក្រោម ៖

ក. ចូរអ្នកពិភាក្សាគ្នា ដើម្បីគូសតារាងដោយប្រើលេខ ឬចំណុចមូលខ្មៅ និងសរសេរបង្ហាញព័ត៌មានអំពីប្រធានបទអ្វីមួយដែលអ្នកបានដឹង ឬបានស្គាល់ ដោយមើលលំនាំតារាងក្នុងអំណានទី ១ ។

ឧទាហរណ៍ : រ៉ែមាសនៅកម្ពុជា

| ឈ្មោះរ៉ែ | ឈ្មោះកន្លែងមានរ៉ែ |
|---|---|
| | |

ខ. ចូរអ្នកសរសេរអត្ថបទខ្លីមួយ ផ្អែកលើតារាងខាងលើឱ្យបានប្រាំល្បះយ៉ាងតិច អំពីប្រធានបទដែលអ្នកបានជ្រើសរើស ។

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................



www.elibraryofcambodia.org

មេរៀនទី ៤

# ប្រយោជន៍នៃធម្មជាតិ



ធម្មជាតិមានទឹកដី ព្រៃព្រឹក្សា បក្សាបក្សី មច្ឆជាតិ ភ្នំ ស្ទឹង បឹងបួ ទន្លេ សមុទ្រ ។ល ។ ធម្មជាតិបានផ្តល់ភាពក្សេមក្សាន្ត និងផ្តល់ប្រយោជន៍ដ៏វិសេសវិសាលដល់មនុស្ស ប៉ុន្តែ មនុស្សបែរជាបំផ្លិចបំផ្លាញធម្មជាតិឥតឈប់ឈរទៅវិញ ។

តើនឹងមានអ្វីខ្លះកើតឡើងចំពោះមនុស្សជាតិ បើធម្មជាតិវិនាសអស់?



www.elibraryofcambodia.org

# ព្រឹត្តិការណ៍រឿង

តើព្រឹត្តិការណ៍ជាអ្វី ? ព្រឹត្តិការណ៍ គឺជាហេតុការណ៍ ដែលកើតមានជាធម្មតានៅក្នុងសង្គម ឬនៅក្នុងរឿងនិទានផ្សេងៗ ។

នៅក្នុងរឿងមួយ តែងមានហេតុការណ៍ផ្សេងៗកើតឡើង ។ សកម្មភាព ឬអ្វីដែលតួអង្គធ្វើ និងជួបប្រទះ ឬអ្វីៗដែលកើតឡើងចំពោះតួអង្គ គឺជាព្រឹត្តិការណ៍រឿង ។

ចូរអ្នកអានរឿងខាងក្រោមនេះ ។ តើរឿងនេះមានព្រឹត្តិការណ៍អ្វីខ្លះ ?

## រឿង ក្ដីប្រាថ្នារបស់កូនឫស្សី

កាលដើមឡើយ មានកូនឫស្សីមួយដើម មិនពេញចិត្តនឹងស្លឹករបស់វាសោះ ។ វាយល់ថា ស្លឹករបស់វាមានរាងវែង ហើយស្ដើងពេកទៀតផង ។ វានិយាយថា វាចង់បានស្លឹកវាដូចមាស បើបានស្លឹកមាសទើបស្អាត ។

រុក្ខទេវតាឮដូច្នោះ ក៏បានធ្វើឱ្យស្លឹករបស់វាក្លាយជាមាសដូចប្រាថ្នា ។ កូនឫស្សីសប្បាយចិត្តណាស់ ។ ក្រោយមក មានបុរសម្នាក់ដើរមកឃើញកូនឫស្សីមានស្លឹកមាស ក៏បេះស្លឹកទាំងនោះយកទៅលក់ទាល់តែអស់ ។

កូនឫស្សីនឹកឃើញថា ស្លឹកមាសមិនសមនឹងវាទេ វាចង់បានស្លឹកដូចកញ្ចក់វិញ ។ រុក្ខទេវតា ក៏ផ្ដល់ស្លឹកកញ្ចក់ឱ្យកូនឫស្សីដូចបំណង ។ កូនឫស្សីពេញចិត្តណាស់ ។ ប៉ុន្តែមិនយូរប៉ុន្មានស្រាប់តែមានភ្លៀងធ្លាក់យ៉ាងខ្លាំង ថែមទាំងមានខ្យល់បក់បោក ធ្វើឱ្យស្លឹកកញ្ចក់នោះបែកខ្ទេចខ្ទីអស់ ។ លើកនេះ កូនឫស្សីផ្សងថា សូមឱ្យវាមានស្លឹកធំៗ ហើយមានពណ៌បៃតងដូចឈើឯទៀតវិញ ។ រុក្ខទេវតា ក៏ជួយសម្រេចក្ដីប្រាថ្នារបស់វាទៀត ។ ប៉ុន្តែបន្តិចក្រោយមក សត្វពពែបានមកដល់ ហើយស៊ីស្លឹកវាគ្មានសេសសល់ ។

កូនឫស្សីនិយាយថា ស្លឹកដែលសក្តិសមនឹងខ្លួនវា មានតែស្លឹកចាស់របស់វាតែប៉ុណ្ណោះ ។ ស្លឹកវែងស្ដើង ដែលធម្មជាតិបង្កើតមក ពិតជាសមចំពោះវាណាស់ ។ រុក្ខទេវតា ក៏ធ្វើឱ្យកូនឫស្សីនោះមានស្លឹកដូចដើមវិញ ។



www.elibraryofcambodia.org

រឿងខាងលើមានព្រឹត្តិការណ៍ចំនួន ៤ ៖

១. កូនឫស្សីមិនពេញចិត្តនឹងស្លឹកកំណើតរបស់វា ហើយចង់បានស្លឹកមាស ។

២. កូនឫស្សីចង់បានស្លឹកកញ្ចក់ ។

៣. កូនឫស្សីចង់បានស្លឹកពណ៌បៃតងហើយធំ ។

៤. កូនឫស្សីចង់បានស្លឹកដូចដើមវិញ ។

ព្រឹត្តិការណ៍នៃរឿង គឺជាហេតុការណ៍ដែលកើតឡើងនៅក្នុងរឿងនិទានផ្សេងៗ ។

**លំហាត់**

**ចូរអានរឿងខាងក្រោម ហើយរកព្រឹត្តិការណ៍នៃរឿង ។**

## រឿង កូនសេក

ព្រឹងជាអ្នកយាមចម្ការដំឡូងរបស់ចៅកែម្នាក់ ។ គេសង់កូនខ្ទមតូចមួយនៅក្បែរជើងភ្នំ ។ ពេលយប់ ព្រឹងតែងប្រទះឃើញសត្វព្រៃមាន ប្រើស ឈ្លូស និងជ្រូកព្រៃដើររកស៊ីក្នុងចម្ការនោះ ។ ពេលថ្ងៃ សត្វបក្សាបក្សីហើរច្រវាត់ពេញព្រៃ ។

ពេលរសៀលមួយ ព្រឹងឃើញកូនសត្វធ្លាក់នៅមុខខ្ទម ។ គេដើរទៅមើលឃើញកូនសេករបួសជើងម្ខាងហើរមិនរួច ។ ព្រឹងរើសកូនសេកថ្នមៗ យកមកលាបថ្នាំឱ្យ ។ ភ្លាមនោះ មេសេកហើរមកស្រែកចេចចាចៗ ចង់ចុះមកយកកូនតែមិនហ៊ាន ។ ព្រឹងនិយាយទៅកាន់សេក ៖ " ឯងកុំភ័យអី ខ្ញុំមិនធ្វើអីកូនរបស់ឯងទេ ។ ចាំវាជា ខ្ញុំនឹងលែងវាឱ្យទៅជួបឯងវិញ " ។ ថាហើយ ព្រឹងយកកូនសេកទៅគ្រុងក្នុងអង្រុត ហើយដាក់ទឹកនិងចំណីឱ្យវា ។ កូនសេកយំរកមេឥតឈប់ ។ ឯមេវាក៏មិនហ៊ានទៅណាឆ្ងាយពីកូនដែរ ។

ពីរបីថ្ងៃក្រោយមក ជើងរបស់កូនសេកបានជាដូចដើម ។ វាហើរចុះហើរឡើងនៅក្នុងអង្រុត ។ ព្រឹងពិនិត្យឃើញថា កូនសេកជាមែនទែនហើយ ក៏លែងវាឱ្យហើរទៅជួបមេវាវិញ ។



www.elibraryofcambodia.org

# រឿង ការភ្ញាក់រឭករបស់ អ៊ំ សែម




ព្រឹកមួយ កសិករចំណាស់ម្នាក់ឈ្មោះសែម បានយកផ្លាកមួយផ្ទាំងទៅបោះភ្ជាប់នឹងទ្វារចូលក្នុងដីដ៏ធំរបស់គាត់ ។ ផ្លាកនោះសរសេរថា " ដីសម្រាប់លក់ " ។

បោះផ្លាករួច អ៊ំសែមក៏ថយក្រោយបន្តិច ដើម្បីអានអក្សរនៅលើផ្លាកនោះ ។ បន្ទាប់មក គាត់អង្គុយចុះ ក្រោមដើមឈើមួយដើម ។

ភ្លាមនោះ មានបុរសពីរនាក់ជិះរថយន្តទំនើបមួយគ្រឿងមកឈប់នៅចំពីមុខគាត់ ។ បុរសម្នាក់ ចុះពីរថយន្តហើយសួរគាត់ ៖ " តើដីនេះសម្រាប់លក់មែន ឬទេ ? តើអ្នកណាជាម្ចាស់ដីនេះ ? " ។

អ៊ំសែម ក្រោកឈរហើយនិយាយដោយយឺតៗ ៖ " បាទ! នេះជាដីសម្រាប់លក់ ហើយវាជារបស់ខ្ញុំ " ។

អ៊ំសែម បាននាំបុរសទាំងពីរដើរមើលដីនោះ ។ នៅពេលឆ្លងកាត់ព្រែក បុរសម្នាក់បាននិយាយ ៖ " យើងនឹងចាក់ដីបំពេញព្រែកនេះ ហើយសង់អគារនៅលើដីនេះ " ។

អ៊ំសែមភ្ញាក់មាត់ ៖ " បំពេញព្រែក ! ដូច្នេះ តើកង្កែបនឹងទៅឯណា ? " ។


www.elibraryofcambodia.org

បុរសម្នាក់ឆ្លើយ ៖ " អូ! វាអាចទៅនៅព្រៃផ្សេងទៀត ។ កង្កែបមិនសំខាន់ទេ " ។

អ៊ីតបរិញ ៖ " ប៉ុន្តែវាសំខាន់ ព្រោះវាស៊ីសត្វល្អិតដូចជាមូសជាដើម " ។

នៅពេលដើរទៅដល់ដើមឈើចំមួយ បុរសម្នាក់និយាយ ៖ " យើងនឹងជួលគេឱ្យកាប់ដើមឈើនេះ យកធ្វើជាអុសលក់ ។ បន្ទាប់មក យើងសង់អគារច្រើនទៀត " ។

លោកអ៊ីចូរតិចៗ ៖ " កាប់ដើមឈើ! កន្លែងនេះនឹងប្រែជាក្តៅខ្លាំងមិនខាន " ។

បុរសម្នាក់ឆ្លើយ ៖ " មែនហើយ ! យើងនឹងដាក់ម៉ាស៊ីនត្រជាក់ និងកង្ហារក្នុងអគារ " ។

អ៊ីនិយាយ ៖ " ដើមឈើជាមិត្តដ៏ល្អ វាសម្អាតខ្យល់ ។ នៅពេលអស់ដើមឈើ ខ្យល់នឹងមិនបរិសុទ្ធទេ " ។

ពួកគាត់នាំគ្នាដើររហូតដល់ទន្លេ ។ បុរសម្នាក់និយាយដោយពេញចិត្ត ៖ " ល្អណាស់ ! កាកសំណល់ចេញពីរោងចក្រនឹងត្រូវបង្ហូរចូលទន្លេនេះ " ។

អ៊ីលែងនិយាយអ្វីទាំងអស់ ប៉ុន្តែគាត់បានស្រមៃឃើញ ទន្លេនោះលែងស្អាតទៀតហើយ ចំណែកត្រីធំៗងាប់ដោយកាកសំណល់នោះ ។

បុរសទាំងពីរបានដកប្រាក់មករាប់ ដើម្បីប្រគល់ជូនអ៊ីសែម ។ ពេលនោះ អ៊ីសែមប្តូរចិត្ត មិនព្រមលក់ដីនោះវិញ ។ គាត់គិតថា បើគាត់លក់ដីនេះ មានន័យថា គាត់បានចូលរួមចំណែកក្នុងការបំផ្លាញបរិស្ថានដែរ ។ គាត់ក៏ប្រាប់ទៅបុរសទាំងពីរ ៖ " ខ្ញុំមិនលក់ដីនេះទេ ព្រោះខ្ញុំមិនចង់បំផ្លាញធម្មជាតិឡើយ " ។

## សំណួរ

១. តើអ៊ីសែមដាក់ផ្លាកសញ្ញាដើម្បីអ្វី ?

២. ហេតុអ្វីបានជាគាត់ចង់លក់ដី ?

៣. តើអ្នកចង់ទិញដី មានគម្រោងធ្វើអ្វីខ្លះ ?

៤. ហេតុអ្វីបានជាអ៊ីសែមសម្រេចចិត្តឈប់លក់ដី ?

៥. តើអ៊ីសែមមានអារម្មណ៍ដូចម្តេច នៅពេលគាត់ឮបុរសទាំងពីរនិយាយពីគម្រោងរបស់ពួកគេ ?



www.elibraryofcambodia.org

៦. តើអារម្មណ៍របស់អ៊ំសែម ត្រូវបានបង្ហាញដោយត្រង់ ឬបង្កប់ ?

៧. តើរឿងនេះមានតួអង្គណាខ្លះ ? តើអ្នកចូលចិត្តតួអង្គណាជាងគេ ? ហេតុអ្វី ?

លំហាត់

ក. ចូររកពាក្យផ្ទុយនឹងពាក្យ ៖

ចំណាស់ ថយក្រោយ អង្គុយចុះ ទំនើប ក្តៅខ្លាំង ល្អ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ ៖ ដី សួរ កំពុង ។

គ. ចូររកពាក្យដែលមានន័យដូចគ្នាមកជំនួសពាក្យដែលមានគំនូសពីក្រោម ។

១. ព្រឹកមួយ <u>កសិករ</u> ចំណាស់ម្នាក់ បានយកផ្លាកទៅបោះភ្ជាប់នឹងទ្វារចូល ... ។

២. មានបុរសពីរនាក់ជិះ<u>រថយន្ត</u> ទំនើបមួយគ្រឿង ។

៣. នៅពេលអស់ដើមឈើ ខ្យល់នឹងមិន<u>បរិសុទ្ធ</u>ទេ ។

ឃ. ចូរបង្ហាញព្រឹត្តិការណ៍នៃរឿងខាងលើ ។

ង. តើរឿងនេះចង់អប់រំដូចម្តេច ? ចូរជ្រើសរើសចម្លើយសមស្របមួយ ។

១. ត្រូវស្រឡាញ់ និងថែរក្សាព្រៃឈើ ។

២. ត្រូវស្រឡាញ់ និងថែរក្សាសត្វផ្សេងៗ ។

៣. ត្រូវស្រឡាញ់ និងថែរក្សាបរិស្ថានធម្មជាតិ ។

ច. តើការឆ្លើយតបរបស់អ៊ំសែម ទៅកាន់បុរសទាំងពីរនាក់ បញ្ជាក់ពីអារម្មណ៍បែបណារបស់គាត់ ? ចូរជ្រើសរើសចម្លើយមួយសមស្រប ។

១. អ៊ំសែមភ័យខ្លាចបាត់បង់ដី ។

២. អ៊ំសែមភ័យខ្លាចបាត់បង់សម្បត្តិធម្មជាតិ ។

៣. អ៊ំសែមឈឺចាប់នឹងសម្តីរបស់បុរសទាំងពីរ ។



www.elibraryofcambodia.org

# ៦ រឿង ស្រីកណ្ដុរល្មោភ




១. តើបុរសមានប្រពន្ធនោះធ្វើអ្វីរាល់ថ្ងៃ ?

២. តើមានហេតុការណ៍អ្វីកើតឡើង នៅពេលគាត់កាប់រលំដើមជ្រៃ ?

៣. តើគាត់យកមាសនោះទៅឯណា ?

៤. ហេតុអ្វីបានជាប្រពន្ធបុរសនោះ ប្រើប្តីឱ្យកាប់ដើមជ្រៃ ?

៥. តើប្រពន្ធបុរសនោះជាមនុស្សដូចម្ដេច ?

៦. តើបុរសរកឃើញមាសដែរឬទេ នៅពេលគាត់រំលំដើមជ្រៃ ?

៧. តើមានអ្វីកើតឡើង នៅទីបញ្ចប់នៃរឿង ?

៨. តើផ្នែកណាមួយនៃរឿងដែលល្អ ?

៩. ហេតុអ្វីទើបអ្នកយល់ថាផ្នែកនេះល្អ ?

១០. តើរឿងនេះចង់អប់រំដូចម្ដេច ?



www.elibraryofcambodia.org

## ១—៧ កិរិយាអកម្ម

កិរិយា គឺជាសព្ទសម្ដែងអំពើ ឬជាពាក្យសម្គាល់សកម្មភាព ។

**ចូរអានឧទាហរណ៍ខាងក្រោម ។ តើពាក្យណាខ្លះជាកិរិយាអកម្ម ?**

៥. គាត់នាំគ្នាដើរ រហូតដល់ទន្លេ ។

១. កង្កែបលោត ។

២. ទឹកហូររឹមៗ ។

៤. ត្រីធំៗនិងងាប់អស់ ។

៣. ដើមជ្រៃរលំ ។

ពាក្យ " ដើរ លោត ហូរ ងាប់ រលំ " ជាកិរិយាដែលពុំមានកម្មបទផ្ទាល់ ឬពាក្យសម្រាប់បំពេញន័យទេ ។ កិរិយាទាំងនេះមានឈ្មោះថា " កិរិយាអកម្ម " ។

> កិរិយាអកម្ម គឺជាកិរិយាដែលមិនត្រូវការកម្មបទផ្ទាល់ ។

**កិរិយាអកម្មមាន ៖** សើច យំ ស្រែក ឈរ អង្គុយ ហើរ លោត ដើរ... ។

### លំហាត់

ក. **ចូររកកិរិយាអកម្មឱ្យបាន ៣ ហើយបង្កើតល្បះនឹងកិរិយាទាំងនោះ ។**

ខ. **ចូរស្រង់កិរិយាអកម្មនៅក្នុងកថាខណ្ឌខាងក្រោម ។**

បុរសចំណាស់អង្គុយក្រោមដើមឈើម្នាក់ឯង ។ គាត់និយាយបណ្ដើរ ក្រោកឈរបណ្ដើរ ។ បន្ទាប់មកគាត់យកដៃអេះក្បាល ហើយដើរទៅមុខទៀតដោយយឺតៗ ។ ពេលនោះស្រាប់តែមេឃងងឹត ខ្យល់បក់បោកពីគ្រប់ទិសទី គាត់ក៏រត់សំដៅមកផ្ទះ ។ ភ្លាមនោះភ្លៀងចាប់ផ្ដើមធ្លាក់យ៉ាងខ្លាំង ផ្គរគ្រហឹមពេញមេឃ ។ ភ្លៀងធ្លាក់ ហ៊ីងក៏ចាប់ផ្ដើមយំប្រណាំងគ្នា ។



www.elibraryofcambodia.org

# យើងរួមគ្នាថែរក្សាបរិស្ថាន



ថ្ងៃនេះ រដ្ឋាសប្បាយចិត្តណាស់ ។ គេនិងឪពុកគេកំពុងជិះរថភ្លើងធ្វើដំណើរទៅកសិដ្ឋានរបស់លោកតាគេ ។

នៅតាមផ្លូវ រដ្ឋាមើលវាលស្រែ ភ្នំ និងសត្វ ហើយនិយាយទៅកាន់ឪពុក ៖ "ប៉ា! ខ្ញុំនឹងទៅហែលទឹកលេងក្នុងទន្លេដ៏ធំ ។ ខ្ញុំនឹងចាប់ត្រីមួយចំនួន និងឡើងដើមឈើទៀត" ។ ឪពុករបស់រដ្ឋាបន្ថែម ៖ " ហើយជិះលើខ្នងក្របី ចាប់កង្កែប និងបេះផ្លែឈើ ដូចប៉ាធ្វើកាលពីក្មេង" ។

បន្ទាប់ពីធ្វើដំណើរយ៉ាងយូរ ពួកគេក៏បានទៅដល់កសិដ្ឋាននោះ ។ លោកតានិងចៅសប្បាយចិត្តណាស់ នៅពេលបានជួបគ្នា ។ ប៉ុន្តែបន្តិចក្រោយមក រដ្ឋាបែរជាក្រៀមក្រំចង់យំទៅវិញ ។ តើមកពីមូលហេតុអ្វី ? រដ្ឋាដឹងថាវាមិនអាចហែលទឹក វាមិនអាចជិះទូក ហើយវាមិនអាចចាប់ត្រីបានទេ ។



www.elibraryofcambodia.org

លោកតាបានប្រាប់វា ៖ " ទន្លេត្រូវបានបំពុលហើយ ។ វាកខ្វក់ណាស់ ត្រីមិនអាចរស់នៅបានទេ ។ រោងចក្របានបង្ហូរទឹកកខ្វក់ចូលក្នុងទន្លេ ចំណែកមនុស្សក៏បំពុលទឹកទន្លេដោយបោះកាកសំណល់ផ្សេងដែរ" ។ កន្លងមក មានការអប់រំអំពីការបំពុលនេះដែរ ប៉ុន្តែយើងត្រូវការពេលយូរ ទើបទទួលបានផល ។

រដ្ឋានិយាយដោយក្រៀមក្រំ ៖ "លោកតា! តើចៅអាចទៅមើលដើមឈើធំៗ និងបេះផ្លែឈើបាន ឬទេ ?" ។ លោកតានិយាយដោយការសោកស្ដាយ ៖ " ឈើជាច្រើននៅក្បែរភ្នំត្រូវគេកាប់អស់ហើយ" ។

ឪពុករដ្ឋាមើលតាមបង្អួច ឃើញដើមឈើតិចតួចប៉ុណ្ណោះ ។ គាត់និយាយ ៖ " ដើមឈើនៅសល់តិចតួចណាស់ ។ ដូច្នេះ សត្វព្រៃក៏ខ្សត់ដែរ " គាត់ងក់ក្បាលតិចៗនិងនិយាយ ៖ "គួរឱ្យសោកស្ដាយណាស់ ប៉ុន្មានឆ្នាំនេះ យើងខ្សត់ទាំងដើមឈើទាំងសត្វ ឯដំណាំស្រូវក៏មិនល្អដែរ ដោយសារទឹកជំនន់ដ៏ធំបានធ្វើឱ្យដីអស់ជីជាតិ ។ ដីគ្មានជីជាតិធ្វើឱ្យបន្លែ និងរុក្ខជាតិមិនអាចលូតលាស់បានទេ ។ សព្វថ្ងៃ កសិករតិចតួចណាស់នៅដាំបន្លែ" ។

រដ្ឋាសួរឪពុកទាំងមិនអស់ចិត្ត ៖ ប៉ា! តើយើងអាចស្ដារស្ថានភាពនេះបាន ឬទេ ? ឪពុករដ្ឋានិយាយ ៖ ប៉ាយល់ថា អ្វីដែលយើងត្រូវធ្វើ គឺយើងនឹងដាំកូនឈើឱ្យបានច្រើននៅតាមកសិដ្ឋាននានា ។ យើងនឹងបានកសិដ្ឋានកូនឈើ " ។

## សំណួរ

១. តើរដ្ឋានិងឪពុករបស់គេ ធ្វើដំណើរទៅឯណា ?

២. តើនៅទីនោះ រដ្ឋាមានគម្រោងនឹងធ្វើអ្វីខ្លះ ?

៣. តើរដ្ឋាបានហែលទឹកទន្លេ និងបានចាប់ត្រីដែរ ឬទេ ? ហេតុអ្វី ?

៤. តើទន្លេត្រូវបំពុលដោយរបៀបណា ?

៥. តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីថែរក្សាបរិស្ថានធម្មជាតិ ?



www.elibraryofcambodia.org

## លំហាត់

ក. ចូរអានពាក្យពហុព្យាង្គ (ពាក្យច្រើនព្យាង្គ) ខាងក្រោម ៖

កសិដ្ឋាន រុក្ខជាតិ កសិករ ។

ខ. ចូរជ្រើសរើសពាក្យមួយ ដែលមានន័យដូចពាក្យ ៖

១. កសិដ្ឋាន ៖

☐ កន្លែងចិញ្ចឹមសត្វ ☐ កន្លែងធ្វើស្រែចម្ការ

☐ កន្លែងដាំដើមឈើ ។

២. រុក្ខជាតិ ៖

☐ ដើមឈើ ☐ រុក្ខជាតិផ្សេងៗ ☐ ផ្លែឈើ ។

៣. កសិករ ៖

☐ អ្នកថែសួន ☐ អ្នកដាំបន្លែ ☐ អ្នកធ្វើស្រែចម្ការ ។

គ. ចូរសរសេរពាក្យផ្ទុយនឹងពាក្យ ៖

សប្បាយចិត្ត លឿន យូរ ក្រៀមក្រំ កខ្វក់ តិចតួច ។

ឃ. ចូររកពាក្យសូរដូចនឹងពាក្យ " ចិត្ត ដី " ។

ង. ចូរបង្ហាញគម្លៃអប់រំនៃរឿង ដោយជ្រើសរើសចម្លើយសមស្របមួយ ។

☐ ១. ត្រូវចូលរួមដាំដើមឈើឱ្យបានច្រើន ។

☐ ២. ត្រូវចូលរួមថែរក្សាបរិស្ថានធម្មជាតិ ។

☐ ៣. ត្រូវជួយអប់រំប្រជាជនកុំឱ្យបំពុលទឹក ។

ច. ចូរស្រង់កិរិយាអកម្មនៅក្នុងអត្ថបទខាងលើ ឱ្យបាន៥ ។

ឆ. ចូរស្រង់ព្រឹត្តិការណ៍នៃរឿងខាងលើតាមលំដាប់លំដោយ រួចសរសេរដាក់ក្នុងសៀវភៅសរសេររបស់អ្នក ។



www.elibraryofcambodia.org

## សញ្ញាផាត់លើ ឬសំយោគសញ្ញា

ក. ឧទាហរណ៍

១. ប្រជាជន នាំគ្នាយកជ័រទឹកពីដើមឈើទាល ។

២. ល៉ិនខ្មែរ មានគុណភាពល្អជាងល៉ិននាំចូលពីបរទេស ។

៣. គាត់អាស្រ័យបាយក្រោមដើមរាំង ។

៤. សូមឱ្យអ្នកឆ្លងផុតគ្រោះភ័យទាំងឡាយ ។

> សញ្ញាផាត់លើសម្រាប់បង្កើតសូរស្រៈ [អ៊ិ] [អ៉ាំ] [អ៊ែ] **និង [អ៊ើ]** ។

ខ. **ទីកន្លែង**

សញ្ញានេះ ប្រើនៅលើព្យញ្ជនៈដើមព្យាង្គ ។

លំហាត់

ក. **ចូររកពាក្យដែលមានសញ្ញាផាត់លើឱ្យបាន៥ពាក្យ ។**

ខ. **ចូរបំពេញល្បះដោយប្រើពាក្យមានសញ្ញាផាត់លើឱ្យបានសមស្រប ។**

១. តើផ្កានេះមាន ... អ្វី ?

២. តើពាក្យនេះមាន ... ដូចម្តេច ?

៣. ទិស ... ស្ថិតនៅចន្លោះទិសបស្ចិម និងទិសឧត្តរ ។

៤. គេបើក ... សៀវភៅអានដោយថ្នមៗ ។

៥. គាត់ក្តៅខ្លាំងហើយរងា ... ដូចគ្រុន ។

គ. **ចូរបង្កើតល្បះនឹងពាក្យនីមួយៗខាងក្រោម ៖**

ជ័យ ប្រល័យ កេងប្រវ័ញ្ច

ឃ. **ចូរអ្នកសរសេររឿងនិទានខ្លីមួយនិយាយអំពីអ្វីមួយ ដែលទាក់ទងនឹងធម្មជាតិដូច**

ជា ព្រៃឈើ ទន្លេ ឬភ្នំ ... ។



www.elibraryofcambodia.org

# ការពណ៌នាអំពីប្រយោជន៍នៃព្រៃឈើ

សំបូរនិងសម្បត្តិ បាននាំគ្នាទៅកម្សាន្តនៅក្នុងឧទ្យានជាតិមួយ ។ ពួកគេ បាននិយាយគ្នាអំពីប្រយោជន៍នៃព្រៃឈើ ។ ចូរអានការសន្ទនាខាងក្រោម ។

សំបូរ : សម្បត្តិ! នៅទីនេះមានដើមឈើច្រើនណាស់ ហើយត្រជាក់ទៀត ។ តើឯងស្គាល់ដើមឈើទាំងនេះទេ ?

សម្បត្តិ : ខ្ញុំស្គាល់ដើមឈើច្រើនណាស់ ពីព្រោះខ្ញុំធ្លាប់ចូលព្រៃជាមួយឪពុកខ្ញុំ ។ នេះជាដើមបេង ។ នេះជាគគីរ ។ នោះជាថ្នឹក និងឈើទាល ។ រីឯដើមត្រង់ហើយមានពណ៌សនោះ ជាដើមស្រឡៅ ។

សំបូរ : តើឯងដឹងថា ដើមឈើមានប្រយោជន៍អ្វីខ្លះ?

សម្បត្តិ : ដើមឈើជាជម្រកសត្វព្រៃ ជាគ្រឿងសំណង់ និងគ្រឿងប្រើប្រាស់ផ្សេងៗ ។ ព្រៃឈើផ្តល់អុសដុត ថ្នាំសង្កូវ ចំណីអាហារមនុស្ស សត្វ ឯស្លឹកឈើធ្វើឱ្យដីមានជីជាតិ ។

សំបូរ : ដើមឈើបញ្ចេញចំហាយទឹកជាពពក ធ្វើឱ្យមានភ្លៀងទៀងទាត់ ។

សម្បត្តិ : នៅមានទៀត ដើមឈើជួយការពារយើងពីកម្តៅព្រះអាទិត្យកុំឱ្យយើងរងកម្តៅខ្លាំង និងស្រូបទឹកភ្លៀងដែលអាចការពារកុំឱ្យមានទឹកជំនន់លិចលង់ខ្លាំងខុសពីធម្មតា ។

សំបូរ : ដោយសារព្រៃឈើមានប្រយោជន៍ច្រើនយ៉ាងនេះ យើងត្រូវតែនាំគ្នាជួយថែរក្សាព្រៃឈើដែលនៅសេសសល់ឱ្យបានគង់វង្ស និងដាំកូនឈើបន្ថែមឱ្យបានច្រើនទៀតមែនទេ ?

សម្បត្តិ : មែនហើយសម្លាញ់ !

លំហាត់

ចូរអ្នកចាប់គូ ឬពិភាក្សាគ្នាតាមក្រុម ដើម្បីរៀបចំការពណ៌នាអំពីប្រយោជន៍នៃដើមឈើណាមួយ ដែលអ្នកបានដាំ ។



www.elibraryofcambodia.org

## សំណេររឿងនិទាន

អ្នកធ្លាប់បានអាន និងស្ដាប់រឿងជាច្រើនមកហើយ ។ រឿងខ្លះមានតួអង្គតិច រឿងខ្លះមានតួអង្គច្រើន ។ រឿងខ្លះមានព្រឹត្តិការណ៍រឿងតែមួយ ដំណើររឿងខ្លី រឿងមួយចំនួនទៀតមានព្រឹត្តិការណ៍រឿងច្រើន ធ្វើឱ្យដំណើររឿងវែង ។

ចូរអ្នកអានអត្ថបទអំណានទាំងពីរ ហើយពិនិត្យមើល តើមានតួអង្គតិច ឬច្រើន ហើយដំណើររឿងវែង ឬខ្លី ។ តើក្នុងរឿងមានព្រឹត្តិការណ៍ប៉ុន្មាន តួអង្គជួបនឹងបញ្ហាអ្វីខ្លះ ឬបានធ្វើអ្វីខ្លះ ?

ចូរអ្នកសរសេររឿងនិទានវែងមួយ ដែលមានតួអង្គច្រើន ។ មុននឹងសរសេរអ្នកត្រូវកំណត់ ៖

- តួអង្គសំខាន់ និងតួអង្គផ្សេងទៀត
- កាលអាកាស ៖
    + ទីកន្លែង (រឿងនោះកើតនៅឯណាខ្លះ ?)
    + ពេលវេលា (រឿងនោះកើតនៅពេលណា ?)
- ព្រឹត្តិការណ៍ (តួអង្គបានធ្វើអ្វីខ្លះ ឬជួបបញ្ហាអ្វីខ្លះ ? តើមានរឿងអ្វីកើតឡើងមុនដំបូង បន្ទាប់មក និងនៅចុងបញ្ចប់នៃរឿង ?)

បន្ទាប់មក អ្នកត្រូវសរសេរព្រាងនៅលើក្រដាសមួយ ។ នៅពេលសរសេរចប់ ចូរអ្នកអាននិងកែលម្អឡើងវិញ ហើយឱ្យមិត្តភក្ដិជួយកែលម្អ ។ នៅចុងបញ្ចប់ អ្នកត្រូវចម្លងរឿងនោះឱ្យបានស្អាតជាការស្រេច ។

អ្នកអាចជ្រើសរើសប្រធានបទ ដែលបានរៀនរួចមកហើយ ឬប្រធានបទណាមួយខាងក្រោម ៖

- ការចូលរួមសម្អាតបរិស្ថានតាមដងព្រែក ឬស្ទឹង ឬទន្លេ
- ការចូលរួមការពារសត្វ
- ការចូលរួមការពារព្រៃឈើ ។



www.elibraryofcambodia.org

មេរៀនទី ៥

# ធនធានជលផលនៅកម្ពុជា



ប្រទេសកម្ពុជាសម្បូរទៅដោយធនធានធម្មជាតិ ពិសេសធនធានជលផលគ្រប់ប្រភេទ ដែលមាននៅក្នុងបឹងទន្លេសាប ស្ទឹង ទន្លេ សមុទ្រ ដូចជាត្រី ក្តាម ខ្យង កំពឹស បង្កង បង្គា មឹក ងាវ ។ ធនធានជលផលទាំងអស់នេះសុទ្ធសឹងផ្តល់ប្រយោជន៍ច្រើនក្រៃលែងចំពោះប្រជាជនយើង ។

តើយើងត្រូវប្រើប្រាស់ និងថែរក្សាការពារដូចម្តេចខ្លះ ដើម្បីឱ្យធនធានជលផលនៅគង់វង្ស ?



www.elibraryofcambodia.org

# តម្លៃអប់រំនៃរឿង

ក្នុងរឿងនីមួយៗ អ្នកនិពន្ធតែងតែបង្កប់នូវអត្ថន័យនៃការអប់រំ ។ ក្នុងការអប់រំនេះ អ្នកនិពន្ធមានវិធីបង្ហាញពីរយ៉ាង ៖

ទី១ : បង្ហាញអំពើល្អ ត្រឹមត្រូវ ស្របច្បាប់ ដើម្បីឱ្យអ្នកអានត្រងត្រាប់តាម ឬ យកជាបទពិសោធន៍សម្រាប់ជីវិត ។

ទី២ : បង្ហាញអំពើអាក្រក់ មិនស្របច្បាប់ ដើម្បីឱ្យអ្នកអានជៀសវាង ។

ចូរអានរឿងខាងក្រោម ។ តើរឿងនេះមានន័យអប់រំដូចម្ដេច ?

## រឿង សត្វភេពីរចែកផ្លូវគ្នារកអាហារ

មានសត្វភេពីរ ភេមួយដើររកត្រីខាងទឹកជ្រៅ ភេមួយទៀតដើររកត្រីខាងទឹករាក់ ។ ថ្ងៃមួយ ភេទាំងពីរចុះស្ទឹងមុជទឹកដេញចាប់ត្រី បានត្រីរ៉ស់មួយ ទើបនាំគ្នាទាញឡើងគោក ដើម្បីចែកគ្នា ។ ភេខាងទឹកជ្រៅទាមទារយកចំណែកខាងក្បាល ព្រោះវាថាវាមានការលំបាកខ្លាំងណាស់ ចំណែកឯភេខាងទឹករាក់ក៏ឆ្លើយថា ចំណែកខាងក្បាលត្រូវបានវាទើបត្រឹមត្រូវ ព្រោះបើវាមិនទំស្ទាក់ចាប់ទេ ក៏មិនបានត្រីនេះដែរ ។ ភេទឹកជ្រៅមិនព្រមចែក ទើបភេទាំងពីរឈ្លោះគ្នា រួចនាំគ្នាទៅរកចចកជាចៅក្រមឱ្យចែកឱ្យ ។

ចចកសួរនាំភេទាំងពីរ បានដឹងរឿងរ៉ាវសព្វគ្រប់ហើយ ក៏កាត់ត្រីនោះជា ៣ភាគ ។ ភាគក្បាលឱ្យភេដែលដើរទឹកជ្រៅ ភាគកន្ទុយឱ្យទៅភេដែលដើរខាងទឹករាក់ ភាគកណ្ដាលចចកយកបរិភោគខ្លួនឯង ។ ភេទាំងពីរ កាលបើឃើញចចកយកភាគកណ្ដាលអស់ដូច្នោះ ក៏តូចចិត្តនឹកស្ដាយចំណីរបស់ខ្លួនពន់ពេកណាស់ ។

តម្លៃអប់រំនៃរឿងខាងលើគឺ " ការលោភលន់ហួសប្រមាណ នាំឱ្យខាតលាភ " ។

តម្លៃអប់រំនៃរឿង គឺជាដំបូន្មាន ឬបទពិសោធន៍ដែលអ្នកអាន អាចទាញយកពីខ្លឹមសារនៃរឿងណាមួយ ។



www.elibraryofcambodia.org

លំហាត់

ក. ចូរអានរឿងខាងក្រោម រួចប្រាប់តម្លៃអប់រំនៃរឿង ដោយជ្រើសរើសចម្លើយមួយសមស្រប ៖

## រឿង កុកនិងក្តាម

នៅក្នុងបឹងមួយមានត្រីតូច ធំ ជាច្រើន ។ នៅពេលទឹករីងហួត ត្រីទាំងឡាយមានការភិតភ័យជាខ្លាំង ។ កុកក្តាប់បានសភាពការណ៍នេះ ក៏ទៅនិយាយប្រាប់ត្រីថាវាបាននាំត្រីទាំងនោះ ទៅរកកន្លែងដែលមានទឹកច្រើន ។ ត្រីទាំងឡាយក៏ជឿ ហើយយល់ព្រមធ្វើតាមកុក ។ បានឱកាស កុកក៏ពាំត្រីទៅស៊ីម្តងមួយៗរហូតដល់អស់ ។ ចុងក្រោយបំផុត កុកក៏នាំយកក្តាមគ្រោងទៅទៀត ។ ទៅដល់គល់ឈើមួយ ក្តាមគ្រោងសង្កេតឃើញមានឆ្អឹងត្រីជាច្រើនគរនៅនឹងគល់ឈើនោះ ។ វាយល់ពីហេតុការណ៍ ដែលកើតមានកន្លងមក ។ ក្តាមគ្រោងដឹងថាកុកយកខ្លួនមកស៊ី ក៏ប្រឹងកៀបកកុកយ៉ាងខ្លាំង រហូតដល់កុកបាត់បង់ជីវិត ។

១. មិនត្រូវសេពគប់អ្នកដែលយើងមិនស្គាល់ប្រវត្តិច្បាស់លាស់ ។

២. មិនត្រូវជឿគេដោយខ្វះការពិចារណា ។

៣. មិនត្រូវជួយអ្នកដទៃដោយសម្លឹងផលប្រយោជន៍ ។

ខ. ចូរអានរឿង "កូនបង្កងចចេស" រួចរកតម្លៃអប់រំនៃរឿង ។

មានកូនបង្កងមួយ រស់នៅក្នុងព្រែកជាមួយនឹងមច្ឆជាតិជាច្រើនទៀត ។ កូនបង្កងនេះ បានអួតពីសម្រស់រាងកាយរបស់វាប្រាប់សត្វឯទៀត ។ វាតែងហែលលេងបង្អួតគេឯងពីសម្រស់របស់វា ។ បង្កងចំណាស់មួយឃើញដូច្នោះ ក៏និយាយណែនាំវា កុំឱ្យបង្ហាញខ្លួននៅលើទឹកត្រូវប្រុងប្រយ័ត្ន ពីព្រោះអ្នកនេសាទច្រើនណាស់ ។

កូនបង្កងឆ្លើយថា ទៅខ្លាចអីអ្នកនេសាទនោះ ។ គាត់មិនងាយចាប់ខ្ញុំបានទេ ខ្ញុំហែលលឿនណាស់ ។ ថាហើយកូនបង្កង ក៏ទៅបបួលមិត្តភក្តិហែលលេងក្បែរៗទូកនេសាទ ។ កូនបង្កងផ្ងៀកផុតពីទឹក ស្រាប់តែអ្នកនេសាទឃើញ ក៏បង់សំណាញ់ចាប់បានកូនបង្កង និងមិត្តភក្តិវាអស់ ។ កូនបង្កងនឹកស្តាយក្រោយ តែហួសពេលទៅហើយ ។



www.elibraryofcambodia.org



អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ពូប្រាក់និងមីងសំ រស់នៅក្នុងភូមិភ្នុកទ្រូ ខេត្តកំពង់ឆ្នាំង ។ គ្រួសារគាត់ បានប្រកបមុខរបរនេសាទត្រី និងធ្វើប្រហុក ផ្អក ត្រីងៀត ត្រីឆ្អើរដែលជាអាជីពប្រចាំគ្រួសារ ។ រដូវសម្រុកមកដល់ ពូប្រាក់និងកូនប្រុសគាត់ពីរនាក់តែងតែចេញទៅនេសាទត្រីតាមទម្លាប់របស់គាត់ ។ ក្នុងមួយឆ្នាំៗ គាត់នេសាទត្រីបានយ៉ាងច្រើន ដើម្បីឱ្យប្រពន្ធ និងកូនស្រីគាត់យកទៅលក់នៅឯផ្សារ ធ្វើប្រហុក ផ្អក ទុកសម្រាប់ហូប និងលក់ដូរ ។ ប៉ុន្តែ ប៉ុន្មានឆ្នាំចុងក្រោយនេះ ពូប្រាក់រកត្រីពុំសូវបានដូចមុនៗទៀតឡើយ ។

ថ្ងៃមួយពេលត្រឡប់មកពីនេសាទវិញ គាត់ត្អូញត្អែរប្រាប់ប្រពន្ធដោយអស់សង្ឃឹម៖ " ម៉ែវាអើយ ! ថ្ងៃនេះ ខ្ញុំរកត្រីមិនបានទេ យើងប្រហែលជាត្រូវដូរមុខរបរហើយ" ។ មីងសំឮដូច្នោះក៏សួរប្ដី ៖ " ហេតុអ្វីបានជាឪវារកត្រីមិនបាន ?" ។ ពូប្រាក់រៀបរាប់ប្រាប់ភរិយា ៖ " ម៉ែវាឯងទេ សព្វថ្ងៃនេះបឹងទន្លេសាបកំពុងទទួលរងគ្រោះធ្ងន់ធ្ងរណាស់ ដោយសារអំពើអគតិរបស់ជនខ្លះ ។ ពួកគេបានទៅកាប់បំផ្លាញព្រៃលិចទឹកជុំវិញបឹង



www.elibraryofcambodia.org

ដែលជាជម្រកត្រីពងនិងបន្តពូជ ដើម្បីយកដីធ្វើស្រែ ។ ម្យ៉ាងទៀត មនុស្សមួយចំនួនធំបានទៅតាំងទីលំនៅលើទឹក ដើម្បីប្រកបរបរនេសាទ លក់ដូរ និងធ្វើសិប្បកម្មផ្សេងៗ ។ អ្នកទាំងនោះ បានបង្ហូរកាកសំណល់ពីលំនៅស្ថាន និងរោងសិប្បកម្ម ដែលមានជាតិពុលទៅក្នុងទឹកបឹងរាល់ថ្ងៃ ធ្វើឱ្យទឹកបឹងកខ្វក់ហើយរាក់ទៅៗ ។ ជាមួយនោះដែរប្រេងម៉ាស៊ីនកាណូតកប៉ាល់ ក៏នាំឱ្យទឹកបឹងកើនកម្ដៅឆាប់រហ័ស បណ្ដាលឱ្យត្រីពុល និងងាយងាប់ ។ ពិសេសទៅទៀត អ្នកខ្លះមានមហិច្ឆតាខ្លាំងពេក បានប្រើមង អួន សំណាញ់ដែលមានក្រឡាញឹកដើម្បីនេសាទត្រី ហើយជនល្មើសច្បាប់ខ្លះទៀតបានប្រើខ្សែភ្លើងឆក់ត្រីធ្វើឱ្យត្រីតូចធំងាប់គ្មានសល់ ។ កត្តាទាំងអស់នេះហើយ ដែលធ្វើឱ្យធនធានជលផលរបស់យើងចេះតែខ្សត់ទៅៗ" ។ " បើយ៉ាងនេះ ពួកយើងនឹងរកត្រីមិនបានថ្ងៃណាមួយមិនខានទេឌីវា ។ " មីងសំស្ងួរប្ដីគាត់ ។ ពូប្រាក់ឆ្លើយឡើង ៖ " មែនហើយ ! បើទោះបីរាជរដ្ឋាភិបាល បានខិតខំអប់រំផ្សព្វផ្សាយច្បាប់នេសាទ និងបំផុសចលនាលែងកូនត្រីតាមបឹងបួយ៉ាងណាក៏ដោយ បើគ្មានអ្នកចូលរួមការពារនោះទេ ធនធានជលផលក៏នឹងវិនាសសាបសូន្យជាមិនខាន ។ បើនៅតែយ៉ាងនេះ ពុំមែនតែក្រុមគ្រួសារយើងទេដែលគ្មានមុខរបរ ឬគ្មានត្រីបរិភោគ គឺប្រទេសជាតិយើងទាំងមូលក៏នឹងធ្លាក់ក្នុងគ្រោះមហន្តរាយផងដែរ" ។

## សំណួរ

១. តើគ្រួសារពូប្រាក់រស់នៅឯណា ?
២. តើគ្រួសារពូប្រាក់ប្រកបមុខរបរអ្វី ?
៣. តើពូប្រាក់ត្អូញត្អែរប្រាប់ប្រពន្ធគាត់អំពីរឿងអ្វី ?
៤. តើបឹងទន្លេសាបកំពុងទទួលរងគ្រោះដោយសារអ្វី ?
៥. តើកត្តាទាំងអស់នោះ ធ្វើឱ្យមានផលប៉ះពាល់ដូចម្ដេចខ្លះ ?
៦. ដើម្បីថែរក្សាធនធានជលផលឱ្យនៅគង់វង្ស តើអ្នកត្រូវធ្វើដូចម្ដេច ?



www.elibraryofcambodia.org

លំហាត់

ក. ចូររកន័យដូចនៃពាក្យ " អាជីព មហន្តរាយ សិប្បកម្ម កត្តា " ដោយជ្រើសរើសចម្លើយត្រឹមត្រូវមួយ ។

១. អាជីព ៖

☐ មុខរបរ ☐ ការចិញ្ចឹមជីវិត ☐ មុខរបរកិច្ចការ ។

២. មហន្តរាយ ៖

☐ សេចក្ដីភិតភ័យ ☐ សេចក្ដីវិនាសធំ ☐ សេចក្ដីវិនាសតិចតួច ។

៣. សិប្បកម្ម ៖

☐ ការធ្វើដោយកម្លាំង ☐ ការជាង ☐ ការច្នៃប្រឌិត ។

៤. កត្តា ៖

☐ ភស្តុតាង ☐ ការផ្ដើមធ្វើ ☐ ការសរុបសេចក្ដី ។

ខ. តើល្បះមួយណាបង្ហាញតម្លៃអប់រំនៃរឿង ?ចូរជ្រើសរើសចម្លើយមួយសមស្រប ។

☐ ១. ត្រូវចូលរួមក្នុងចលនាលែងកូនត្រីនៅតាមបឹងបួ ។

☐ ២. ត្រូវខិតខំបង្កើតមុខរបរនេសាទនៅបឹងទន្លេសាប ។

☐ ៣. ត្រូវចូលរួមថែរក្សាការពារធនធានជលផលនៅបឹងទន្លេសាប ។

គ. ចូរប្រាប់ព្រឹត្តិការណ៍ទាំងអស់ក្នុងរឿងខាងលើ ។

ឃ. ចូរអ្នកសរសេររឿងខ្លីមួយដោយមើលរូបភាពខាងក្រោម ។





www.elibraryofcambodia.org



ត្រីប៉ាសេអ៊ី

ត្រីប៉ាសេអ៊ី ជាត្រីមួយប្រភេទដែលកម្រមាន ហើយជាត្រីដែលមានតម្លៃបំផុតនៅភូមិភាគឦសានក៏ដូចជានៅទូទាំងប្រទេស ។

ត្រីប៉ាសេអ៊ី ជាប្រភេទត្រីស្រកា និងមានរូបរាងស្រដៀងនឹងត្រីព្រួល ។ ត្រីនេះមានប្រវែងពី២០សង់ទីម៉ែត្រ ទៅ៥០សង់ទីម៉ែត្រ និងមានទម្ងន់ពីមួយគីឡូក្រាម ដល់បីគីឡូក្រាម ។ វាយកក្អែលថ្ម និងក្អែលឈើជាអាហារ ។ ត្រីប៉ាសេអ៊ីច្រើនរស់នៅតាមថ្ម ព្រៃលិចទឹក អន្លង់ជ្រៅ និងទឹកហូរ ។ អ្នកនេសាទបានឱ្យដឹងថា ត្រីប៉ាសេអ៊ីជាប្រភេទត្រីដែលមានតែនៅក្នុងអាងទន្លេបួន គឺទន្លេសេកុង សេសាន ស្រែពក និងទន្លេមេគង្គនៃខេត្តស្ទឹងត្រែងប៉ុណ្ណោះ ។ ក្នុងមួយឆ្នាំ ត្រីប៉ាសេអ៊ី ធ្វើការផ្លាស់ទីចំនួនពីរលើកជាទៀងទាត់ គឺលើកទី១នៅដើមខែធ្នូដល់ខែមករា វាឡើងមកទន្លេសេសាននិងស្រែពក ចូលទៅក្នុងទន្លេសេកុង រួចឡើងទៅក្នុងតំបន់ទន្លេមេគង្គភាគខាងលើរហូតដល់តំបន់ល្បាក់ខោននៃព្រំដែនប្រទេសកម្ពុជា - ឡាវ ។ លើកទី២ពីខែមេសា ដល់ខែឧសភា វាត្រឡប់ឡើងទៅទន្លេស្រែពកវិញ ។ អាស្រ័យហេតុនេះ ទើបគេអាចនេសាទត្រីនេះបានតែពីរដងប៉ុណ្ណោះក្នុងមួយឆ្នាំ ។

គេអាចយកត្រីប៉ាសេអ៊ីទៅធ្វើម្ហូបបានច្រើនមុខ ពិសេសស្ងោរជ្រក់មានឱជារសឆ្ងាញ់ពិសាលើសត្រីឯទៀត ។ ដូច្នេះ អ្នកនេសាទគប្បីគោរពច្បាប់នេសាទគ្រប់គ្នា ដើម្បីថែរក្សាមច្ឆជាតិរបស់យើងឱ្យគង់វង្ស ពិសេសពូជត្រីដ៏កម្រនេះ ។



www.elibraryofcambodia.org

លំហាត់

ក. ចូរអ្នកសរសេរកថាខណ្ឌពណ៌នាអំពីត្រីខាងក្រោម ដោយគ្រាន់តែប្រាប់ឈ្មោះ និង រៀបរាប់អំពីរូបរាងរបស់វាតែប៉ុណ្ណោះ ។



ខ. ចូរអ្នកគូររូបត្រីមួយ ដែលអ្នកបានស្គាល់ច្បាស់ ឬ អ្នកបានចិញ្ចឹម រួចផាត់ពណ៌វាទៅតាមធម្មជាតិ ។ បន្ទាប់មក ចូរអ្នកសរសេរអត្ថបទខ្លីមួយ ពណ៌នាអំពីត្រីនោះឱ្យបានក្បោះក្បាយ ។

ក្នុងការសរសេរអ្នកត្រូវគោរពតាមគម្រោងតែងខាងក្រោម ៖

គម្រោងតែង

១. សេចក្ដីផ្ដើម

- ពេលវេលា និងទីកន្លែងចិញ្ចឹម
- ឈ្មោះត្រី កន្លែងរស់នៅ

២. តួសេចក្ដី

- រូបរាង ពណ៌សម្បុរ ប្រវែង ទម្ងន់ ក្បាល ព្រុយ ស្រកា ស្រគី កន្ទុយ ...
- ចំណី
- ផលប្រយោជន៍

៣. បញ្ចប់សេចក្ដី

ចំណាប់អារម្មណ៍របស់អ្នកសរសេរ ។



www.elibraryofcambodia.org

# រឿង ដំណើរកម្សាន្តនៅអន្លង់ត្រីផ្សោត

ចូរស្ដាប់រឿងដែលបានសរសេររួចហើយឡើងវិញ ។



## សំណួរ

១. តើអ្នកណា ធ្វើដំណើរទៅមើលត្រីផ្សោត ?

២. តើត្រីផ្សោតមាននៅឯណា ?

៣. តើបច្ចុប្បន្នត្រីផ្សោតមានតិច ឬច្រើន ?

៤. ហេតុអ្វីបានជាត្រីផ្សោតមាននៅសល់តិច ?

៥. តើតំបន់ដែលមានត្រីផ្សោត បានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជន ?

៦. តើរាជរដ្ឋាភិបាលបានធ្វើអ្វីខ្លះ ដើម្បីអភិរក្សត្រីផ្សោត ?

៧. តើតួអង្គណាមួយ ដែលកំពុងនិយាយប្រាប់រឿងនេះ ?

## លំហាត់

ចូរអានល្បះខាងក្រោមនេះ ។ តើល្បះមួយណាផ្តល់តម្លៃអប់រំនៃរឿងខាងលើ ?

☐ ១. ត្រូវជិះទូកកម្សាន្តមើលត្រីផ្សោត ។

☐ ២. ត្រូវខិតខំអភិរក្សត្រីផ្សោត ។

☐ ៣. ត្រូវទំទាញយកប្រយោជន៍ពីត្រីផ្សោត ។



www.elibraryofcambodia.org

## ៣-៦ កិរិយាសកម្ម

ចូរអានល្បះខាងក្រោមនេះ និងសង្កេតមើលពាក្យអក្សរដិត ។

១. មីងសំប្រឡាក់ត្រី ។

២. ពួកគេធ្វើផ្អក ប្រហុក ត្រីងៀត ។

៣. ពូប្រាក់នេសាទត្រីនៅបឹងខ្នែសាប ។

៤. ប្រជាជនយើងបរិភោគត្រីច្រើនជាងសាច់ ។

៥. ខ្ញុំចូលចិត្តបង្គាស្រស់ជាងបង្គាក្រៀម ។

៦. ហ្វូងត្រីចឹកចំណីនៅក្នុងទឹក ។

៧. ពូសុខបបួលខ្ញុំទៅចាប់ក្ដាម ។

ពាក្យ " ប្រឡាក់ ធ្វើ នេសាទ បរិភោគ ចូលចិត្ត ចឹក បបួល " ក្នុងល្បះខាងលើ បង្ហាញអំពើ ។ វាជា " កិរិយា " ។ កិរិយាទាំងនេះមាននាម កន្សោមនាម ឬសព្វនាម នៅជាប់ខាងស្ដាំ ។ កិរិយាទាំងនេះហៅថា " កិរិយាសកម្ម " ។ ពាក្យ " ត្រី ផ្អក ប្រហុក ត្រីងៀត ត្រី បង្គា ចំណី ខ្ញុំ " ដែលនៅខាងស្ដាំកិរិយាជា " កម្មបទផ្ទាល់ " ។

> កិរិយាសកម្ម ជាកិរិយាដែលមាននាម កន្សោមនាម ឬសព្វនាម នៅជាប់ខាងស្ដាំ ឬជាកិរិយាត្រូវការកម្មបទផ្ទាល់ ។

### លំហាត់

ក. ចូរស្រង់កិរិយាសកម្មនៅក្នុងល្បះខាងក្រោម ៖

១. ជីដូនខ្ញុំពិសាបាយជាមួយត្រីប្រៃ ។

២. សំនិងសានស្ងួចត្រី ។

៣. ពូសៅជួសមង ។

៤. ពួកគេទិញឧបករណ៍នេសាទ ។



www.elibraryofcambodia.org

៥. ពួកគេការពារព្រៃលិចទឹក ។

៦. ពូសានចិញ្ចឹមត្រីប្រាក្នុងស្រះក្បែរផ្ទះ ។

៧. ឆ្នាំនេះមីងម៉ៅធ្វើប្រហុក ផ្អកបានច្រើន ព្រោះប្ដីគាត់ជាអ្នកនេសាទ ។

៨. គេអាំងមឹកធំៗនៅឆ្នេរសមុទ្រកែប ។

**ខ. ចូររកកិរិយាសកម្មនៅក្នុងចំណោម កិរិយាខាងក្រោម ៖**

ទិញ ស្ទូច យំ លក់ នេសាទ រុត រងាវ ចាប់ កាប់ ព្រុស ធ្វើ មើល ភ្ជួរ ។

**គ. ចូររកកិរិយាសកម្មឱ្យបាន១០ពាក្យក្រៅពីកិរិយាសកម្មខាងលើ ។**

## រឿង សុបិនចម្លែក



ស្នេះនិងម៉ារីណា ជាបងប្អូនបង្កើត រស់នៅក្នុងភូមិមួយជិតបឹងធំ ។ ពួកគេប្រកបរបរលក់ត្រីនៅតាមភូមិជាច្រើនឆ្នាំមកហើយ ។ ក្រោយមក មុខរបររបស់ពួកគេជួបការលំបាក ដោយសារអ្នកនេសាទចេះតែឡើងថ្លៃត្រីឥតឈប់ឈរ ។ ហេតុនេះ ស្នេះសម្រេចចិត្តនេសាទត្រីខ្លួនឯងវិញ ។



www.elibraryofcambodia.org

ល្ងាចមួយ ស្នេះប្រាប់ប្អូនស្រីឱ្យរកម្ហូបអាហារទុកបម្រុងយកទៅនេសាទនៅព្រឹកស្អែក រួចក៏និទ្រាលក់ទៅ ។ យប់នោះ ស្នេះយល់សប្តិឃើញថា ខ្លួនគេរកត្រីមិនបានសោះពេញមួយថ្ងៃ ។ លុះដល់ពេលជិតត្រឡប់មកវិញ ស្រាប់តែគេបង់សំណាញ់បានត្រីធំមួយ ។ គេដោះត្រីចេញពីសំណាញ់ដោយត្រេកអរពន់ពេក ស្រាប់តែត្រីនោះនិយាយមករកគេ ៖ " សូមអ្នកដោះលែងខ្ញុំទៅ ! ខ្ញុំជាស្តេចត្រីហើយកំពុងមានពងពេញពោះទៀតផង ។ បើអ្នកទុកជីវិតឱ្យខ្ញុំ ខ្ញុំនឹងបញ្ជូនកូនចៅខ្ញុំមកឱ្យអ្នកបរិភោគរាល់ថ្ងៃ អ្នកមិនបាច់បារម្ភទេ" ។ ឮសម្តីត្រីអង្វរ ស្នេះលើកត្រីបម្រុងលែងទៅក្នុងទឹកវិញ តែម៉ារីណាស្រែកឃាត់ ៖ " បងឆ្កួតទេឬ យើងចំណាយកម្លាំងមួយថ្ងៃ ទើបបានត្រីមួយនេះ ហេតុអ្វីក៏បងចង់លែងត្រីទៅវិញ ? ត្រីពងបែបនេះឆ្ងាញ់ណាស់ ហើយលក់ក៏បានថ្លៃណាស់ដែរ ។ កុំលែងវាអី !" ។ ស្នេះរារែកក្នុងចិត្ត ហើយទីបំផុតក៏លើកត្រីដាក់ក្នុងទូក រួចនាំបងប្អូនត្រឡប់មកគេហដ្ឋានវិញ ។

មកដល់ផ្ទះ ម៉ារីណាកាត់ត្រីទុកខ្លះសម្រាប់ហូប ហើយត្រីនៅសល់នាងយកទៅលក់បានប្រាក់យ៉ាងច្រើន ។ នាងសប្បាយចិត្តណាស់ ។ ថ្ងៃបន្ទាប់ ម៉ារីណាចាប់ផ្តើមក្តៅខ្លួន ។ ស្នេះរត់រកពេទ្យមកព្យាបាលប្អូនតែមិនធូរស្រាលសោះ ។ ក្រោយមក ម៉ារីណាក៏ធ្លាក់ខ្លួនឈឺធ្ងន់ ។ ស្នេះភ័យពេកស្រែកយំយ៉ាងខ្លាំង រហូតដល់ភ្ញាក់ពីដំណេកវិញ ។

ស្អែកឡើង ស្នេះនិយាយរឿងប្រាប់អ្នកនេសាទម្នាក់ ។ បុរសនោះនិយាយថា នេះប្រហែលជាប្រផ្នូលរារាំងស្នេះមិនឱ្យទៅរកត្រីហើយ ព្រោះរដូវនេះជារដូវត្រីពង គេហាមមិនឱ្យនេសាទទេ ព្រោះនាំឱ្យពាយត្រី ។ បើគេចង់នេសាទ ត្រូវរង់ចាំឱ្យផុតរដូវត្រីពងសិន ដើម្បីឱ្យមច្ឆជាតិនៅតែសម្បូរជារៀងរហូត ។ ស្នេះយល់ហើយ ក៏ត្រឡប់មកផ្ទះវិញរង់ចាំឱកាសមកដល់គេនឹងទៅនេសាទ ។



www.elibraryofcambodia.org

## សំណួរ

១. តើស្នេះប្រកបមុខរបរអ្វី ?

២. តើមានរឿងអ្វីកើតឡើងចំពោះស្នេះ ?

៣. ហេតុអ្វីបានជា គេមិនឱ្យនេសាទនៅរដូវត្រីពង ?

៤. តើរឿងនេះមានព្រឹត្តិការណ៍ប៉ុន្មាន ? គឺអ្វីខ្លះ ?

## លំហាត់

ក. ចូរស្រង់កិរិយាសកម្មនៅក្នុងអត្ថបទឱ្យបានចំនួន៥ ។

ខ. ចូរស្រង់ពាក្យដែលមានន័យដូចគ្នា នៅក្នុងអត្ថបទខាងលើ ។

គ. ចូរបង្ហាញតម្លៃអប់រំនៃរឿងនេះ ។

ឃ. ចូររកពាក្យស្នូរដូចនិងពាក្យ " កី ជា " ។

ង. ចូររកពាក្យផ្ទុយនឹងពាក្យ ៖ តម្លើង ត្រេកអរ ស្លាប់ សម្បូរ ។

## សំណេរ

ចូរមើលរូបភាពខាងក្រោម រួចតែងកំណាព្យខ្លី ១វគ្គ បទពាក្យប្រាំពីរ ឬ បទកាកគតិ ។





www.elibraryofcambodia.org

## ការរៀបរាប់ពីធនធានជលផល

ដារ៉ានិងធីតាបានរៀបរាប់អំពីធនធានជលផលដែលមាននៅក្នុងតំបន់របស់គេ ។ ចូរអានការរៀបរាប់ខាងក្រោម ។



ខ្ញុំរស់នៅខេត្តព្រះសីហនុ ។ ទីនោះជាតំបន់សមុទ្រ ។ នៅសមុទ្រសម្បូរក្តាម បង្គា មឹក ងាវ ខ្យង គី បបែល និងត្រីច្រើនប្រភេទទៀត ។ ត្រីសមុទ្រមានរសជាតិឆ្ងាញ់ណាស់ ។

ខ្ញុំរស់នៅតាមដងទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង ។ នៅខេត្តនេះមានត្រីទឹកសាបច្រើនប្រភេទ ក្នុងនោះមានត្រីឥតស្រកា និងត្រីមានស្រកា ។ ត្រីទឹកសាបដែលមានរសជាតិឆ្ងាញ់ហើយមានតម្លៃថ្លៃ គឺត្រីឆ្ពោក ត្រីសណ្តាយ ត្រីក្រំ ត្រីព្រួល ត្រីព្រលូង... ។ ចំណែកត្រីដែលមានរសជាតិឆ្ងាញ់បំផុត គឺត្រីប៉ាសេអ៊ី ។ ក្រៅពីត្រីទាំងនេះ បង្កងទឹកសាបក៏មានរសជាតិឆ្ងាញ់មិនចាញ់ត្រីប៉ាសេអ៊ីឡើយ ។ ត្រីដែលមានមាឌធំជាងគេបង្អស់ ដែលគេចាត់ទុកថាជាស្តេចត្រីក្នុងទន្លេ គឺត្រីរាជ ។



### លំហាត់

ចូរអ្នករៀបរាប់ពីធនធានជលផលដែលមាននៅក្នុងភូមិ ស្រុករបស់អ្នក ប្រាប់មិត្តរួមថ្នាក់ឱ្យបានក្បោះក្បាយ ។



www.elibraryofcambodia.org

# ការរៀបរាប់ឡើងវិញព្រឹត្តិការណ៍មួយក្នុងរឿង

នៅក្នុងរឿងសុបិនចម្លែកមានព្រឹត្តិការណ៍ចំនួន៤ ៖

១. ស្លេះនិងម៉ារីណោប្រកបមុខរបរលក់ត្រីនៅតាមភូមិ ។

២. ស្លេះប្រាប់ប្អូនស្រីឱ្យរកម្ហូបអាហារទុកយកទៅនេសាទ ។

៣. ស្លេះយល់សប្តិចាប់បានស្តេចត្រី ។

៤. ស្លេះយករឿងយល់សប្តិប្រាប់អ្នកនេសាទម្នាក់ ។

ខាងក្រោមនេះជាការសរសេរព្រឹត្តិការណ៍ទី៣ នៃរឿងសុបិនចម្លែកឡើងវិញ ។ ចូរអ្នកអានហើយកត់ចំណាំពាក្យពេចន៍ដែលគេបានប្រើដើម្បីបង្ហាញ ការសរសេរឡើងវិញដោយផ្តល់ទស្សនៈរបស់តួអង្គណាមួយនៅក្នុងព្រឹត្តិការណ៍នោះ ។

## ព្រឹត្តិការណ៍មួយនៃរឿងសុបិនចម្លែក

បន្ទាប់ពីសម្រេចចិត្តប្រកបរបរនេសាទ ស្លេះដេកយល់សប្តិឃើញថាវាចាប់បានស្តេចត្រីមួយដែលកំពុងមានពង ។ ស្តេចត្រីនោះ បានអង្វរស្លេះឱ្យដោះលែងវាទៅវិញ ដោយធានាថានឹងផ្តល់ត្រីឱ្យស្លេះរាល់ថ្ងៃ ។ ស្លេះរៀបនឹងលែងត្រីទៅវិញ ស្រាប់តែប្អូនស្រីរបស់គេបានស្រែកឃាត់ មិនឱ្យគេលែងត្រីនោះទេ ។ មកដល់ផ្ទះ នាងយកត្រីនោះទៅលក់ ហើយកាត់ត្រីទុកខ្លះសម្រាប់បរិភោគ ។ ស្រាប់តែភ្លើងឆាបឆេះផ្ទះ ស្លេះភ័យនិងប្អូនខ្លាំង ក៏យំរហូតដឹងខ្លួន ។ ស្លេះបាននិយាយរឿងនេះប្រាប់អ្នកជិតខាងម្នាក់ ។ បុរសនោះគាត់យល់ថា ប្រហែលជាស្លេះគិតច្រើនពេកទើបយល់សុបិនបែបនេះ ។ ម្យ៉ាងទៀត ពេលដែលស្លេះយល់សប្តិ ជារយៈពេលដែលគេបិទការនេសាទ ដើម្បីឱ្យត្រីពង និងបន្តពូជឱ្យបានច្រើន ។ បើគ្មានរឿងយល់សប្តិនេះ ស្លេះនឹងទៅនេសាទហើយសមត្ថកិច្ចខាងជលផលនឹងចាប់ផាកពិន័យស្លេះជាមិនខាន ។



www.elibraryofcambodia.org

## សំណួរ

១. តើតួអង្គណាបានផ្ដល់ទស្សនៈ ឬការយល់ឃើញនៅក្នុងព្រឹត្តិការណ៍នៃរឿងនេះ ?

២. តើតួអង្គនោះផ្ដល់ទស្សនៈដូចម្ដេចខ្លះ ?

## លំហាត់

**ក. ចូរជ្រើសរើសរឿងណាមួយដែលអ្នកពេញចិត្ត ឬធ្លាប់ចងចាំ ឬរឿងដែលអ្នកទើបនឹងតែង ហើយរកព្រឹត្តិការណ៍ទាំងអស់នៃរឿងនោះ ។**

បន្ទាប់មក ចូរអ្នកជ្រើសរើសព្រឹត្តិការណ៍មួយនៃរឿងនោះ ហើយសរសេរឡើងវិញ ហាក់ដូចជាតួអង្គណាមួយផ្ដល់ទស្សនៈ ឬការយល់ឃើញរបស់ខ្លួននៅក្នុងព្រឹត្តិការណ៍នោះ ។

នៅពេលសរសេររួច ចូរអានផ្នែកដែលអ្នកសរសេរឡើងវិញឱ្យសិស្សក្នុងថ្នាក់ ឬតាមក្រុមស្ដាប់ ។

**ខ. ចូរអ្នកសរសេរអត្ថបទខ្លីមួយ រៀបរាប់អំពីធនធានជលផលនៅក្នុងភូមិស្រុក ឬខេត្តរបស់អ្នកដោយ ៖**

- ប្រាប់ឈ្មោះ ភូមិស្រុក ឬខេត្តរបស់អ្នក
- រៀបរាប់អំពីជលផលដែលអ្នកបានដឹងនៅក្នុងភូមិស្រុកនោះ
- ការចូលរួមថែរក្សា ការពារធនធានទាំងនោះមិនឱ្យបាត់បង់ផុតពូជ ។



www.elibraryofcambodia.org

មេរៀនទី ៦

# ទំនៀមទម្លាប់ ប្រពៃណីខ្មែរ



ខ្មែរយើងមានទំនៀមទម្លាប់ដ៏ល្អផូរផង់ តាំងពីយូរលង់ណាស់មកហើយ ។ ប្រពៃណីទាំងនោះមានដូចជា ព្រះរាជពិធីផ្សេងៗ ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបូជាសព និងពិធីបុណ្យជាច្រើនទៀត ។ ពិធីទាំងនេះ ត្រូវបានប្រជាជនយើងគោរពយ៉ាងខ្ជាប់ខ្ជួន តាំងពីបុរាណកាលរហូតមកដល់បច្ចុប្បន្ន ។

ដូច្នេះយើងជាកូនខ្មែរ ត្រូវបន្តគោរព និងចូលរួមថែរក្សាទំនៀមទម្លាប់ប្រពៃណីទាំងនោះឱ្យបានគង់វង្ស ។



www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្លៅ យ៉ាតណៃ, ខ្លៅ សុផល, ខ្លៅ វិសាល, ខ្លៅ រ៉ាមុន, ខ្លៅ ភារាដា, ខ្លៅ ចំរើន និង ខ្លៅ ភារី បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្លៅ ពាញ និង ឧបាសិកា ឈរ យឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ ដួង កញ្ញា
ខែកុម្ភៈ ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្ថែមទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "កម្មសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្លៅ ឃុនសំរិង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org